# អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម

BUDDHISM FOR SOCIAL DEVELOPMENT ACTION

# របាយការណ៍ប្រចាំឆ្នាំ ២០១៥

## ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

**ទំនាក់ទំនង ៖ លោក ថន វណ្ណង**

**នាយកប្រតិបត្តិអង្គការ**

អាសយដ្ឋាន៖ ផ្លូវខេមរៈភូមិន្ទ ភូមិទី១៤ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម, ប្រទេសកម្ពុជា

ទូរស័ព្ទ.: ០១២៧៨៨៩៧៣

គេហទំព័រ: www.bsda-cambodia.org

សារអេឡិចត្រូនិច: director@bsda-cambodia.org

# មាតិកា


១. សេចក្ដីផ្ដើម ..... 4

ក. ប្រវត្តិអង្គការ ..... 4

ខ. អត្តសញ្ញាណអង្គការ ..... 4

គ. ការកំណត់នូវគុណតម្លៃ ..... 4

ឃ. ទស្សនៈវិស័យ ..... 5

ង. បេសកកម្ម ..... 5

ច. គោលដៅរបស់អង្គការ ..... 5

២. កម្មវិធីរបស់អង្គការ ..... 6

២.១-កម្មវិធីអប់រំ ..... 6

២.១.១. គម្រោងកុមារមេគង្គកម្ពុជា ..... 6

១-ផ្ដល់អាហារូបករណ៍ ..... 7

២-កុំព្យូទ័រ និងអង់គ្លេស ..... 7

៣-បណ្ដុះបណ្ដាលបំនិនជីវិត ផ្នែករបាំប្រពៃណីខ្មែរ និងភ្លេង ..... 8

៤-មណ្ឌលសប្បាយសប្បាយ ..... 9

៥-មណ្ឌលភូមិកុមារវាលស្រែ ..... 10

៦-សាលាថ្នាក់បម្រុងបន្ថែមនៅមណ្ឌលកុមារវាលស្រែ ..... 11

៧-កម្មវិធីថែទាំសុខភាពបឋមនៅមណ្ឌលកុមារ ..... 11

៨-កម្មវិធីថែទាំបន្ត ..... 12

៩-កម្មវិធីសហាគ្រិនភាពសង្គម ..... 12

២.១.២. គម្រោងសមាគមកម្ពុជាដើម្បីកុមារក្រៅសាលា ..... 13

១). កុមារ OOSC ដែលស្ថិតនៅក្រោមការគ្រប់គ្រងគម្រោង ត្រូវបានបានគាំទ្រ និងជួយអោយពួកគាត់ អាចបញ្ចប់ការសិក្សាអប់រំក្នុងកំរិតបឋមសិក្សា ..... 13

២). គុណភាពការអប់រំត្រូវបានពង្រឹង ..... 16

៣). មេដឹកនាំអប់រំ / អ្នកផ្ដល់សេវាត្រូវបានដាក់ល្អប្រសើរជាងមុនដើម្បីកែលម្អការអប់រំដែលមានប្រសិទ្ធិភាព ..... 18

៤). បរិស្ថានអប់រំត្រូវបានធ្វើឱ្យប្រសើរឡើងតាមរយៈការតស៊ូមតិ និងការស្រាវជ្រាវ ..... 19

៥). បញ្ហាប្រឈម និងយុទ្ធសាស្ត្រ ..... 20

២.១.៣. គម្រោងការអប់រំជាមូលដ្ឋាន ..... 21

១).ដោយចុងបញ្ចប់នៃឆ្នាំ 2018 នេះការគាំទ្រសាលារៀនរបស់អង្គការសង្គ្រោះកុមារអន្តរជាតិ សម្រេចបាននូវលទ្ធផល

ល្អប្រសើរជាងមុននៅក្នុងការរៀនសូត្រអក្ខរកម្ម ....................................................................21
២).នៅចុងឆ្នាំ ២០១៨ អង្គការសង្គ្រោះកុមារអន្តរជាតិនឹងជួយគាំទ្ររហូតដល់ ៣០០សាលារៀន........................23

៣)មេរៀនបទពិសោធន៍ ..............................................................................................................25

៤)បញ្ហា.....................................................................................................................................25

២.២-កម្មវិធីសុខភាព...................................................................................................................26

២.២.១-បង្ការ ការថែទាំ និងការគាំទ្រ អ្នករស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍នៅតាមសហគមន៍................26

១).ការរួមបញ្ចូលសេដ្ឋកិច្ចគ្រួសារ និងការបណ្តុះបណ្តាលជំនាញ .......................................................26

២). ពង្រឹងសមត្ថភាពស្ថាប័ន .....................................................................................................26

៣). យែនឌ័រ (ការបណ្តុះបណ្តាល, ការប្រជុំ SHG, អំពើហឹង្សាទាក់ទិននឹងយែនឌ័រ និងព្រឹត្តិការណ៍ផ្សេងៗ............27

៤). ការថែទាំ និងគាំទ្រសម្រាប់អ្នកផ្ទុកមេរោគអេដស៍ ....................................................................28

៥). បទពិសោធន៍ដែលបានរៀនសូត្រកន្លងមក..................................................................................29

២.២.២ - គម្រោងការធ្វើអោយប្រសើរឡើងនូវជីវភាព (PLI) ................................................................29

១). ផ្តល់ការបណ្តុះបណ្តាល ផ្នែកចិញ្ចឹមមាន់ និងផ្តល់ប្រាក់កំចី មុនពេលដែលយើងបានផ្តល់នូវប្រាក់កម្ចី...............30

២). ចុះត្រួតពិនិត្យ និងបង្រៀនការចិញ្ចឹម.......................................................................................30

៣). បង្កើតប្រាក់ចំណូលតាមរយៈការលក់ និងបង្វិលប្រាក់កម្ចីនៃការចិញ្ចឹមមាន់..........................................30

៤). ការប្រជុំប្រចាំខែជាមួយ អ្នកសន្សំប្រាក់តាម ............................................................................31

៤.សន្និដ្ឋាន..................................................................................................................................31

# របាយការណ៍ស្ដីពីលទ្ធផលការងារ
# សម្រាប់ឆ្នាំ ២០១៥

## ១). សេចក្ដីផ្ដើម

### ក. ប្រវត្តិអង្គការ

អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍសង្គម (BSDA) គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយដែលបានបង្កើតឡើងនៅថ្ងៃទី ០៥ ខែមករា ឆ្នាំ២០០៥ ដោយព្រះសង្ឃ៧អង្គនៅវត្តនគរបាជ័យក្នុង និងទទួលស្គាល់ដោយក្រសួងមហាផ្ទៃ តាមប្រកាសលេខ ១៦២ ស.ជ.ណ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៥ ។ BSDA មិនធ្វើការបម្រើឱ្យគណបក្សនយោបាយណា ឬក៏ផ្សព្វផ្សាយ ពីសាសនា របស់សមាជិកខ្លួនឡើយ។ BSDA គឺផ្តោតតែលើការអភិវឌ្ឍន៍សង្គម និងជួយប្រជាជនក្រីក្រ ដែលកំពុង រស់នៅក្នុងសហគមន៍ក្រីក្រ។

### ខ. អត្តសញ្ញាណអង្គការ

BSDA គឺជាអង្គការធ្វើការជាមួយសហគមន៍ ដែលត្រូវបានបង្កើតឡើងនៅលើគោលការណ៍ ព្រះពុទ្ធសាសនានៃមេត្តាធម៌ដើម្បី ផ្តល់អំណាយដល់ប្រជាពលរដ្ឋ ដែលងាយរងគ្រោះនិងដើម្បី លើក កំពស់ការចូលរួមទំនាក់ទំនងល្អដោយ ក្តីអាណិតស្រឡាញ់នៅក្នុង សង្គម ហើយជួយធ្វើអោយការអភិវឌ្ឍន៍សេដ្ឋកិច្ចកាន់តែខ្លាំង ដើម្បីរួមចំណែកលុបបំបាត់ភាពក្រីក្រនិងសេចក្តីទុក្ខដែលអាចជៀសផុតបាន។

### គ. ការកំណត់នូវគុណតម្លៃ

ដោយផ្អែកទៅលើពាក្យប្រៀនប្រដៅពីការអនុវត្តធម៌មេត្តារបស់ព្រះពុទ្ធអង្គ[1] (BSDAបានគោរពតាមនូវគុណតម្លៃដូចខាងក្រោម៖

- **បំរើជនក្រីក្រ៖** ធ្វើអោយបានប្រសើរឡើងនូវជីវភាពរស់នៅរបស់គ្រួសារដែលក្រីក្រ។
- **រួបរួមសាមគ្គី៖** កសាងនូវការជឿជាក់គ្នា ភាពស្មោះត្រង់ និងការគោរពគ្នាទៅវិញទៅមកជាគ្រួសារតែមួយ។
- **យុទ្ធសាស្រ្តបែបប្រជាធិបតេយ្យ៖** លើកតម្កើងអោយមានសម្លេងរួមគ្នា មកពីសមាជិកសហគមន៍ដៃគូធ្វើការជាមួយ បុគ្គលិកគ្រប់លំដាប់ថ្នាក់ និងការភ្ជាប់ពួកគេទៅនឹងដំណើរការ នៃការធ្វើសេចក្តីសម្រេចចិត្ត។
- **ការសហការគ្នា៖** ធ្វើការទាំងអស់គ្នា និងជាដៃគូជាមួយអ្នកផ្សេងៗដែលមកពីទីណាក៏ដោយ អោយតែអាច ដើម្បីពង្រីកផលជះរបស់ពួកយើង។

---

1 មេត្តា = ការសាបព្រួសនូវការស្រលាញ់ដែលមិនអាត្មានិយម ហើយនិងក្តីមេត្តា ជាជាងសាបព្រួសនូវភាពជាមិត្តដែលផ្អែកលើផលប្រយោជន៍ផ្ទាល់ខ្លួន។

- ***សុចរិតភាព និងគណនេយ្យភាព៖*** នៅក្នុងការគ្រប់គ្រងនិងការប្រើប្រាស់ជំនួយ ត្រូវប្រកបដោយគណនេយ្យភាពនិងតម្លាភាពដល់សហគមន៍ ម្ចាស់ជំនួយនិងអ្នកធ្វើការជាមួយគ្នា។

## ឃ .ទស្សនៈវិស័យ

BSDA ប្រថ្នាចង់ឃើញសង្គមមួយ ដែលប្រជាពលរដ្ឋរស់នៅដោយឯករាជ្យ និងអាចចិញ្ចឹមជីវិតដោយខ្លួនបាន។

## ង .បេសកកម្ម

បេសកកម្មរបស់BSDA គឺលើកកំពស់ជីវភាពរស់នៅរបស់ប្រជពលរដ្ឋ ដែលងាយរងគ្រោះ ជាពិសេសស្ត្រី និងកុមារ និងយុវជន តាមរយៈវស័យអប់រំ សុខភាព និងការផ្តួចផ្តើមអភិវឌ្ឍន៍ ជីវភាព ការរស់នៅជាដៃជាមួយអ្នកផ្សេងទៀត។

## ច .គោលដៅរបស់អង្គការ

-ដើម្បីជួយដល់កុមារនិងយុវជនដែលងាយរងគ្រោះ អោយមានភាពប្រសើរក្នុងការទទួល បានការអប់រំ និងលើសពីនេះទៅទៀតយុវជនត្រូវបានផ្តល់នូវជំនាញបច្ចេកទេសតាមរយៈ ការបណ្តុះ បណ្តាលវិជ្ជាជីវៈដែលធានាអោយមានជីវភាពប្រកបដោយនិរន្តរភាព។

-ដើម្បីធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសហគមន៍ តាមរយៈការអាចកាន់តែទទួលបានសេវាថែទាំសុខភាពតាមសហគមន៍ ដែលប្រកបដោយគុណភាព និងធ្វើអោយយល់ដឹងពីផ្នែកសំខាន់ៗ នៃសុខភាពសាធារណៈកាន់តែល្អប្រសើរឡើង។

-ដើម្បីអោយប្រសើរឡើង ត្រៀមសម្រាប់ការផ្លាស់ប្តូរអាកាសធាតុ ដោយការបង្កើនការយកចិត្តទុកដាក់បន្ថែមទៀតក្នុងការការពារបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។

-ដើម្បីធ្វើអោយមានអភិបាលកិច្ចកាន់តែល្អ ជាការថែមទៅលើផែនការដែលមានស្រាប់ និងការផ្តល់ សេវាសាធារណៈក្នុងការបំពេញនូវតម្រូវការសហគមន៍អោយបានរឹងរិតតែល្អ។

-ដើម្បីធ្វើអោយប្រជាពលរដ្ឋនៅជនបទ ដែលមិនទួលបានផលប្រយោជន៍អ្វី អោយមានឱកាសអាចបង្កើតចំណូលបាន និងគាំទ្រអោយមាននិរន្តរភាព និងបង្កើតសកម្មភាព ដែលមិនរកប្រាក់កម្រៃចំណេញរបស់អង្គការ ដើម្បីពង្រីកផលអោយបានកាន់តែប្រសើរថែមទៀត។

## ២). សកម្មភាពរបស់អង្គការ

### ២.១-កម្មវិធីអប់រំ

#### ២.១.១. គម្រោងកុមារមេគង្គកម្ពុជា

ក. គោលបំណង៖ ជួយគាំទ្រដល់ក្មេងកំព្រា ងាយរងគ្រោះ ក្មេងបាត់បង់ឱកាស និងក្មេង ដែលនៅតាមចិញ្ចើមថ្នល់ ផ្តល់គុណភាពនៃការរស់នៅរបស់ពួកគេ អោយកាន់តែប្រសើរឡើង។

ខ. ចំនួនបុគ្គលិកសរុប ៖ ៩ នាក់ ស្រី: ៥ នាក់

គ. ទីតាំងគម្រោង ៖ ខេត្តកំពង់ចាម វត្តនគរបាជ័យក្នុង

ឃ. សរុបថវិកាគម្រោង ៖ 263204.27ដុល្លា

ង. កាលបរិច្ឆេទគម្រោង ៖ខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៥

ច. សកម្មភាពអនុវត្តគម្រោង៖

| ក្រុមកុមារ OVC | អ្នកទទួលផលផ្ទាល់ពីគម្រោង<br>ចាប់ពី ខែ មករា- ខែធ្នូ ២០១៥ | |
|---|---|---|
| | សរុប | ស្រី |
| I-អាហារូបករណ៍: | | |
| 1 . អាហារូបករណ៍សិស្សក្រីក្រនៅសហគមន៍ | ៩០ | ៤៨ |
| 2. អាហារូបករណ៍ ម្តាយធម៌ | ៩ | ៦ |
| 3. អាហារូបករណ៍ កុំព្យូទ័រ | ៤០ | ២៧ |
| 4.អាហារូបករណ៍ រៀនភាសាអង់គ្លេស | ៥៩១<br>(១៨នាក់ ជាសិស្សមកពីអាហារូបករណ៍សិស្សក្រីក្រនៅសហគមន៍) | ៣២៦<br>(ស្រី ១៥នាក់ជាសិស្សមកពីអាហារូបករណ៍សិស្សក្រីក្រនៅសហគមន៍) |
| II-សិស្សបណ្តុះបណ្តាលវិជ្ជាជីវ | ២៧ | ១៣ |
| III. សិស្សថៃទាំបន្ត(សិស្សចប់ជំនាញ) | ៧១ | ៤៥ |
| IV-បណ្តុះបណ្តាលបំនិនជីវិតផ្នែក របាំប្រពៃណីខ្មែរ និងភ្លេង | | |
| 1. សិស្សមណ្ឌលអប្សរា | ១០៣ | ៦៣ |
| 2. សិស្សមណ្ឌលសប្បាយសប្បាយ | ១០១ | ៥០ |
| សរុប | ៩៥៧ | ២៦៤ |

## ១-ផ្តល់អាហារូបករណ៍

ក្នុងឆ្នាំ២០១៥ គម្រោងកុមារមេតង្គកម្ពុជាបានផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រតាមសាលាក្នុងស្រុកកំពង់សៀម និងស្រុកកំពង់ចាម សរុប សិស្ស ៩០នាក់ (ស្រី ៤៨) ក្នុងនោះសិស្សម្នាក់ទទួលបាន អង្ករ ២៣គក, ប្រេងឆា ១លីត, ស្ករ១គក, អំបិលអ៊ីយ៉ូត កន្លះគក, ទឹកត្រី១ដប, ទឹកស៊ីអ៊ីវ១ដប និងត្រីខ១កំប៉ុង ស្មើរនឹងទឹកប្រាក់ ១៥ដុល្លារសហរដ្ឋអាមេរិច ជារៀងរាល់ខែ។ ក្រៅពីនេះ គម្រោងបានផ្តល់សម្ភារៈសិក្សាដល់សិស្សទាំងអស់ក្នុងម្នាក់ៗទទួលបាន សៀវភៅ ប៊ិច ខ្មៅដៃ បន្ទាត់ ជ័រលុប កាប៉ូក មួយចប់ និង សំលៀកបំពាក់១កំផ្លេ ម្តងក្នុងមួយឆ្នាំ។ អាហារូបករណ៍នេះទទួលបានជំនួយពី អង្គការ អេកូសូលីដារ នៅប្រទេសស្វីស។

ក្នុងឆ្នាំនេះដែរ សិស្សក្រីក្រពិសេសផ្សេងទៀតចំនួន ៩ នាក់ (ស្រី៧នាក់) បានទទួលការឧបត្ថម្ភគាំទ្រពីម្តាយធម៌ របស់សមាគមន៍មួយនៅប្រទេសបារាំង( Les Enfant Du Wat Norkor Association) និង មួយក្រុមទៀត មកពីសហរដ្ឋអាមេរិក តាមរយៈ ក្រុមហ៊ុន Rustic Pathways និងមកពីប្រទេសស្វីស អាឡឺម៉ង់។ សិស្សម្នាក់ៗទទួលបាន អង្ករ ២៣គីឡូ និង ប្រាក់សុទ្ធ ១៩.០០ដុល្លា ផ្តល់សម្រាប់ការបង់ថ្លៃសិក្សា និង ចំណាយប្រចាំថ្ងៃជារៀងរាល់ខែ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| សិស្សមួយចំនួនតូច នៅតែបោះបង់ការសិក្សា ទោះបី គម្រោងបានលផ្តល់អាហារូបករណ៍ ដើម្បីគាំទ្រដល់ពួកគេដោយ។ នេះដោយសារការ គាំទ្ររបស់យើង មិនបានគ្រប់គ្រាន់ សម្រាប់គ្រួសាររបស់ធំពួកគេ ដូច្នេះពួកគាត់សម្រេចចិត្តឈប់រៀនដើម្បីរកប្រាក់ចំណូលជួយគ្រួសារវិញ | គម្រោងបានទៅជួបអាណាព្យាបាលដើម្បីពិគ្រោះយោបល់ និងស្វែងរកមូលហេតុអោយបាន ច្បាល់ថា តើហេតុអ្វីបានជាពួកគាត់ត្រូវការ គាំទ្រច្រើន។ គម្រោងនឹងព្យាយម ជជែកជាមួយម្ចាស់ជំនួយ ក្នុងការផ្តល់អាហារូបករណ៍ច្រើនជាងមួយក្នុងមួយគ្រួសារ ប្រសិនបើពួកគេពិតជាត្រូវការការគាំទ្រសម្រាប់ក្រុមគ្រួសារធំរបស់ពួកគេ។ |

## ២-កុំព្យូទ័រ និងអង់គ្លេស



ថ្នាក់បង្រៀនកុំព្យូទ័រ គម្រោងបានផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ នៅកំរិតអនុវិទ្យាល័យ ចំនួន ៤០នាក់ (ស្រី ២៧)។ វគ្គសិក្សាមាន គ្រប់គ្រង់រដ្ឋបាលទូទៅ(Microsoft Words, Excel, Power Point, Photoshop, Publisher) និង Computer Repair ដែលបង្រៀនដោយគ្រូស្មគ្រ័ចិត្ត ព្រះតេជគុណ ហេង ហៀន មកពីវត្តនគរបានជ័យក្នុង ហើយជា បុគ្គលិកផ្នែកពត៌មានវិទ្យារបស់អង្គការដែរ។

ការផ្ដល់ការសិក្សាថ្នាក់ភាសាអង់គ្លេសបន្ថែម មានបួនកន្លែងនៅមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ (មណ្ឌលកុមារវាលស្រែ) ចំនួន ២៥នាក់ ស្រី១៤នាក់, មណ្ឌលអប្សរា ១៨នាក់ ស្រី១៥នាក់, មណ្ឌលសប្បាយ



សប្បាយ ១០១នាក់ ស្រី ៥០នាក់ សិស្សទាំងអស់ ត្រូវបានបង្រៀនដោយឥតគិតថ្លៃ

និងការអប់រំសីលធម៌សង្គម ដើម្បីបន្ទន់ឥរិយាបថ សម្រាប់ប្អូនៗជំនាន់ថ្មី។ រីឯថ្នាក់ភាសាអង់គ្លេសនៅ បឋមសិក្សានិងអនុវិទ្យាល័យអង្គរវៀងរាល់ម៉ោង ៥ ដល់ ម៉ោង ៧ល្ងាច ទទួលបានសិស្សចំនួន ៥៩១នាក់ ស្រី ៣២៦នាក់ ពួកគាត់ ទទួលបានចុះតម្លៃ ៥០% ធៀបទៅនឹងសាលាឯកជន ដែលគេយក ១០០% សម្រាប់សិស្សក្រីក្រ។

## ៣). បណ្ដុះបណ្ដាលបំនិនជីវិតផ្នែក របាំប្រពៃណីខ្មែរ និងភ្លេង

នៅមណ្ឌលសិល្បៈអប្សរា បានបណ្ដុះបណ្ដាលដល់ក្មេងៗ ដែលនៅជុំវិញវត្តនគរបាជ័យ និងក្មេងនៅក្នុង សហគមន៍មួយចំនួនទៀតមកពី សហគមន៍ ៤២ខ្នងជាដើម និងសហគមន៍ចាក់សម្រាមបឹងស្នាយ ចំនួន ១០៣ នាក់ ស្រី៦៣នាក់។ គម្រោងបានដឹកជញ្ជូនពួកគាត់ពីសហគមន៍ ទៅមករោងសិល្បៈដោយប្រើយានជំនិះ កង់បីជារៀងរាល់ថ្ងៃ ដើម្បីកុំអោយពួកគាត់ពិបាកធ្វើដំណើរ។ ការមករៀននៅទីនេះអង្គការបានផ្ដល់អាហារសម្រន់ជារៀងរាល់ថ្ងៃដែរ។ ជាលទ្ធផលពួកគាត់អាចសំដែងជូនភ្ញៀវ និងពិធីផ្សេងៗបាន



ដូចជារបាំជូនពរ, នារីជាជួរ, អប្សរា,គោះត្រឡោក, ក្រមា, ក្ងោកបៃលីន, បុកលក្ខ័, ឆៃយ៉ាំ... និងរបាំត្រុដិជាដើម។ សម្រាប់ប្អូនតូចៗ ត្រូវបានផ្ដល់ការបណ្ដុះបណ្ដាលបន្តពីសិស្សបងៗ ជាបន្តបន្ទាប់។ ឆ្នាំនេះផងដែរ ក្រុមសិល្បៈ ដែលដឹកនាំដោយក្រុមសិស្សច្បងទាំង៦នាក់បានដឹកនាំចេញសំដែងបាន ១៦ដងតាមកម្មវិធីផ្សេងៗក្នុងខេត្តកំពង់ចាម និងខេត្តផ្សេងទៀតបានយ៉ាងល្អ ប្រកបដោយទំនុកចិត្តខ្ពស់ បន្ទាប់ពី



អតីតលោកគ្រូតារបស់ពួកគាត គឺលោកគ្រូ ពិន សុខុមបានលាឈប់សំរាកទៅ។

ចំណែកភ្លេងប្រពៃណីទើបតែចាប់ផ្ដើមនៅ ឆមាស ទីពីរ ២០១៥ មានសិស្សចំនួន៤៥នាក់(ស្រី៣៨) ដែលចេញមកពីក្រុមសិស្សរបាំ ពួកគាត់ទទួលបាន ការបង្ហាតភ្លេងពិណពាទ្យ និងភ្លេងប្រពៃណីខ្មែរ(ភ្លេងការ) បង្ហាត់ដោយ គ្រូ សួរ ម៉ិល(ហៅភ្លីមុត) ជំនាញភ្លេងប្រពៃណី និងអាយ៉ៃ និងលោកគ្រូ ម៉េង ហុង

អតីតសិស្សជនពិការ មកពីអង្គការគ្រួសារថ្មី។ រាល់បទភ្លេងដែលបានបង្រៀនគឺ សាច់ភ្លេងទូទៅ និងសាច់ភ្លេងសម្រាប់បង្គុំរាំរបាំប្រពៃណី និងអប្សរា។ ជាលទ្ធផលពួកគាត់ ទទួលបាន ២ ទៅ ៥បទ នៃសាច់ភ្លេងសម្រាប់ រាំរបាំនេះ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| នៅមានការខ្វះសម្ភារៈប្រើប្រាស់ភ្លេងប្រពៃណី | គម្រោងបានខិតខំស្វែងរកថវិការបន្ថែមដើម្បីទុកសម្រាប់ការជួសជុល និងពង្រឹងវិន័យក្នុងប្រើប្រាស់ចៀសវាងការខូចខាត។ |

## ៤). មណ្ឌលសប្បាយសប្បាយ

នៅមណ្ឌលសប្បាយសប្បាយ គម្រោង កុមារមេគង្គកម្ពុជា ហៅកាត់ថា (MKK) និងគម្រោងសមាគមន៍គម្ពុជាដើម្បីកុមារក្រៅ សាលា (CCOSC) បានកំពុងអនុវត្ត គម្រោងអប់រំ ក្រៅប្រពន្ធ័ គឺបង្រៀនចំណេះដឹងទូទៅ សុខភាព អនាម័យ និងភាសាអង់គ្លេសត្រៀមមុនចូលរៀន និងកំពុងសិក្សា។ សរុបឆ្នាំ ២០១៥នេះ សិស្ស ដែលបាន ទទួលសេវាពីមណ្ឌលសប្បាយសប្បាយចំនួន ១០១នាក់ (ស្រី ៥០នាក់)។ លើសពីនេះទៀត បុគ្គលិកគម្រោងបានចុះផ្សព្វផ្សាយចំណេះដឹងដល់សហគមន៍ ស្តីអំពី ការកាត់បន្ថយ អំពើហឹង្សារ ក្នុងគ្រួសារ, សិទ្ធិកុមារ, សារៈសម្ខាន់នៃការសិក្សា,ពលកម្មកុមារ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ អាណាព្យាបាលរបស់សិស្សទាំងអស់ ចំនួន ១៥ ដង/វគ្គ ដែលមានអ្នកចូលរួមសរុប ២៣៧នាក់ (ស្រី១១៧) និង ក្មេង២៦នាក់ (ស្រី១៨) នៅតាមសហគមន៍គោលដៅ។ ជាលទ្ធផលធ្វើអោយកូនៗ របស់ពួកគាត់មានចំណេះដឹងកើន លែងមានការបោះបង់ ការសិក្សារបស់ពួកគាត់ប្រសើរជាមុន។ យោងតាមការធ្វើតេស្តប្រឡងបង្ហាញអោយឃើញថា ៣២% នៃសិស្សនៅមណ្ឌលសប្បាយសប្បាយ មានពិន្ទុកំរិតល្អ, ២៣%ល្អបង្គួរ, ៣៨%មធ្យម ហើយ ៧%ដែលពិន្ទុទាប នេះបើយោងតាមលទ្ធផល ឆ្នាំកន្លងទៅមានការកើនឡើងខុសពីធម្មតា។




ចំពោះអាគារ និងបរិវេណមណ្ឌលសប្បាយសប្បាយ ត្រូវបានអនុញ្ញាតិពីមន្ទីរសង្គមកិច្ច ខេត្តកំពង់ចាម អោយប្រើប្រាស់ និងអោយមានការកែឆ្នៃ ឬសង់បន្ថែមនិងកែលំអរផ្សេងៗ ដើម្បីជា ប្រយោជន៍ដល់កុមារក្រីក្រនៅសហគមន៍ក្រីក្រនៃក្រុងកំពង់ចាម។ ក្នុងឆ្នាំកន្លងមក រហូតដល់ឆ្នាំ ២០១៥ មណ្ឌលសប្បាយសប្បាយបានសង់របង ធ្វើអំពីលួសបន្លាពទ្ធ័ជុំវិញ, ក្លោងទ្វារ, ចាក់ដីដារបំពេញ, លាបថ្នាំពណ៌អាគារឡើងវិញ,ជួសជុលបន្ទប់ទឹក, សង់ទីធ្លាសួនកុមារ និងសម្អាតបរិស្ថានជុំវិញបរិវេណ មណ្ឌល បានលទ្ធផលប្រសើរគួរអោយកត់សំគាល់ពីអាណាព្យាបាលក៏ដូចញាតិមិត្តជិតខាងផងដែរ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|

| | |
|---|---|
| បរិស្ថាននៅមណ្ឌល មិនស្អាតនៅពេលមានភ្លៀងធ្លាក់ ដោយសារប្រពន្ធ័លូនៅម្តុំនោះមិនស្តង់ដារ | ស្នើរសុំអជ្ញាធរពាក់ពន្ធ័ភូមិឃុំ និងវិស្វកម្មបច្ចេកទេសចុះត្រួតពិនិត្យនិងសង់លើងវិញ |

## ៥). មណ្ឌលភូមិកុមារវាលស្រែ

ក្នុងឆ្នាំ ២០១៥ នៅចុងឆមាសទី1 សិស្សជំនាន់ទីIII បានបញ្ចប់វគ្គចំនួន ២៥នាក់ ហើយអង្គការបានធ្វើសមាហារណកម្មពួកគាត់ទៅសហគមន៍វិញ។ ចំណែកជំនាន់ទីIV បានចាប់ផ្តើមបន្តវគ្គថ្មី ក្នុងឆមាសទីII មានចំនួន ២៧នាក់ (ស្រី១២) ក្នុងនោះមានសិស្សពីរនាក់ ដែលបានធ្វើសមាហារណកម្ម ពីអង្គការ ផ្ទះកុមារ ខេត្តកំពង់ចាម និង វត្តអំពត ខេត្តតាកែវ។ ក្នុងឆ្នាំនេះមណ្ឌលបានកើន សិស្ស ២នាក់បន្ថែមទៀត។

### ក-ការងារសាងសង់



យោងតាមការផែនការសាងសង់អាគារដែលមានដូចជា អាគារស្នាក់នៅសម្រាប់ក្មេងស្រី និង ក្មេងប្រុស អាគារសម្រាប់អាហារដ្ឋាន សាលារៀន សាលាបណ្តុះបណ្តាល វិជ្ជាជីវៈ និងហេដ្ឋារចនាសម្ពន្ធ័ផ្សេងៗ ទៀនៅក្នុងបរិវេណមណ្ឌលបានបញ្ចប់រួចរាល់ហើយនោះ អង្គការនៅតែមាន គម្រោងសាងសង់ និងជួលជុលបន្តរហូត ទៅតាមលទ្ធភាព។ ដោយឡែកនៅឆ្នាំ ២០១៥នេះគម្រោងបានសាងសង់ ដំបូលបន្លែ, អណ្តូង ប្រពន្ធ័ទឹក សួនបន្លែបែបធម្មជាតិគ្មានគីមី និងដាំដើមឈើ និងដំណាំហូបផ្លែនៅមុខបរិវេនមណ្ឌល ជាប្រយោជន៍ដល់សិស្សរស់នៅក្នុងមណ្ឌល។

### ខ-ផលិតផលសន្តិសុខស្បៀង និងការផ្តល់ជំនាញការចិញ្ចឹមជីវិតដល់សិស្ស

**-ការចិញ្ចឹមមាន់ៈ** បន្ទាប់ពីទ្រុងមាន់បានសាងសង់រួចរាល់ គម្រោងក៏បានពង្រីកទីធ្លាបន្ថែម ដោយប្រើសំណាញ់ហ៊ុំពទ្ធ័ ដើម្បីអោយសត្វមាន់អាចដើរចេញពីទ្រុង និងស្រូបយកបរិកាសនៃរស្មីសំយោគ និងជាការបន្សាំអាកាសធាតុនៃជីវិតរបស់មាន់។ ម្យ៉ាងទៀតយើងធ្វើបែបនេះ ដើម្បីការពារកុំអោយស៊ីបន្លែដែលយើងបានដាំនៅក្បែរៗនោះ។ សម្រាប់ឆ្នាំ២០១៥ សរុបមាន់ដែលកំពុងចិញ្ចឹម មានចំនួន ៣៦ក្បាល មេ២០ក្បាល កូន១២ក្បាល។ រហូតមកដល់ចុងឆ្នាំ យើងបារចិញ្ចឹមសត្វទា១០ក្បាល មេ៨ក្បាល បន្ថែមទៀត ដើម្បីផលិតស៊ុតសម្រាប់ការផ្គត់ផ្គង់អាហារហូបចុកប្រចាំថ្ងៃរបស់ក្មេងៗកំពុងសិក្សាជំនាញ។ ម្យ៉ាងទៀតនោះវាជាផ្នែកមួយនៃបំពេញបន្ថែម និងការទ្រទ្រង់ការចិញ្ចឹមជីវិតប្រចាំថ្ងៃ របស់សិស្សមណ្ឌល និងការកាត់បន្ថយចំណាយការទិញម្ហូបប្រចាំថ្ងៃរផងដែរ។

**-ការដាំបន្លែៈ** សួនបន្លែនៅឆ្នាំ ២០១៥ គម្រោងបានរំពឹងទុកចំពោះដំណាំកសិកម្មសរីរាង្គ គ្មានជាតិគីមីនេះ នឹងយកមកផ្គត់ផ្គង់អាហារប្រចាំថ្ងៃក្នុងមណ្ឌល។ លើពីនេះទៀតគម្រោងប៉ាន់ប្រមាណថា នៅឆ្នាំ ២០១៦ តទៅខាងមុខ ការចំណាយថ្លៃម្ហូបប្រចាំថ្ងៃ ត្រូវបានកាត់បន្ថយចំនួន ២៦%នៃការ





ចំណាយសរុបប្រចាំថ្ងៃ។ បន្ថែមពីនេះទៀត ដាំមាន ត្រកួន កញ្ជែត ហើយវារស់តាមបែបធម្មជាតិ មិនប្រើជាតិគីមី ដោយវាលូតលាស់តាមជីធម្មជាតិដែលនៅ ជុំវិញ មណ្ឌល ដំណាំនេះ ពួគប្រើប្រាស់ជារៀងរាល់ថ្ងៃពេលដែល សម្រាប់បំពេញតម្រូវការក្នុងខណៈពេល ម្ហូបទិញពីផ្សារមិនគ្រប់គ្រាន់។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| មានមួយចំនួនមានជំងឺដោយសារឆ្លងមេរោគតាមអាកាសធាតុប្រែប្រួល។ | ចាក់វ៉ាក់សាំងការពារទាំងមាន់តូច និងធំហើយដាំដើមឈើនៅក្បែទ្រុងនិងជាប្រយោជន៍ការផ្តល់ចំណី និងម្លប់សម្រាប់មាន់ |
| -ចំពោះបន្លែនៅតែមានសត្វល្អិតមកស៊ីបំផ្លាញបន្លែធម្មជាតិ<br>-ដីដែលកំពុងដាំបន្លែភាគច្រើនសម្បូរទៅដោយជាតិអាស៊ីត ធ្វើអោយបន្លែលូតលាស់យឺត។ | -បុគ្គលកគម្រោងនឹងបង្កើតជាតិពុរធម្មជាតិដើម្បីបណ្តេញសត្វទាំងនោះចេញ<br>-បុគ្គលិកជំនាញនឹងប្រើប្រាស់កំបោរកសិកម្មដើម្បីកាត់បន្ថយជាតិអាស៊ីត។ |

## ៦). សាលាថ្នាក់បម្រុងបន្ថែមនៅមណ្ឌលកុមារទាលស្រែ

ថ្នាក់ត្រៀមបានផ្តល់ជូនដល់សិស្សជំនាញជំនាន់ទី៣មុនពេលពួកគេបញ្ចប់ជំនាញនៅ ចុងឆមាសទី I ជាលក្ខណសិក្ខាសាលា និងបណ្តុះបណ្តាលដូចជា ផែនការអនាគតមុនចេញទៅរកមុខរបរ ផែនការទីផ្សាររបៀបចាប់ផ្តើអាជីវកម្មថ្មី និងរបៀបសរសេរបែបបទ ដើម្បីរកការងារធ្វើ។ នេះដើម្បីប្រែកដថា ពេលពួកគាត់ចេញពីមណ្ឌលបណ្តុះបណ្តាលទៅ ពួកគាត់ធ្វើការអ្វី។ ចំណែកជំនាន់ទី IV ទើបតែជ្រើសរើសបានថ្មីអោយចូលរៀននៅក្នុងត្រីមាសទី២ ត្រូវបានផ្តល់ការសិក្សាចំណេះដឹងទូទៅ ដូចជា គណិតវិទ្យា អានភាសាខ្មែរ ភាសាអង់គ្លេសមុនពួកគាត់ចាប់យកជំនា ហើយក្រៅពីនេះ កម្រោងផ្តល់វគ្គសិក្ខាសា ផែនការផ្សេងៗដូចមុនៗដែរ។ បន្ទាប់ពីពួកគាត់បានចប់សាលាថ្នាក់ត្រៀម បុគ្គលិកគម្រោងបានធ្វើបទបង្ហាញមួយស្តីអំពីការណែនាំតម្រង់ទិសដល់ពួកគាត់មុនពេលចាប់យកជជំនាញ។ ដោយឡែក ឆ្នាំ២០១៥ នេះ សិស្សជំនាញដែលមានចំនួន ២៧នាក់ សិស្សកាត់ដេរ ៧នាក់ ជាងជួសជុលម៉ូតូ ១០នាក់ ចុងភៅ ៩នាក់ ម៉ាស៊ីនត្រជាក់ ១ជំនាញទាំងអស់គឺរៀន នៅសាលាខាងក្រៅ លើកលែងតែ ផ្នែកចុងភៅ គឺរៀននៅមណ្ឌល។

## ៧). កម្មវិធីថែទាំសុខភាពបឋមនៅមណ្ឌលកុមារ

សិស្សទាំង ២៧នាក់មានការមើលថែទាំពីអ្នកគ្រូពេទ្យជាប្រចាំក្នុងមណ្ឌល។ ២២នាក់ ស្រី ១១នាក់ ទទួលបានការចាក់ វ៉ាក់សាំងការពារតេតាណុះ និងមានសិស្ស៣នាក់ទៀតផ្ទុកមេរោគជំងឺអេដស៍ ទទួលបានការថែទាំដោយយកចិត្តទុកដាក់ និងប្រុងប្រយត្ន័។ សម្រាប់សិស្សដែលមានជម្ងឺធ្ងន់ធ្ងរ អង្គការនឹងបញ្ជូន ទៅមន្ទីរពេទ្យខេត្តដើម្បីជួយព្យាបាលដោយឥតគិតថ្លៃ និងមានការសហការយ៉ាងល្អ។ ក្រៅពីនេះទៀត ពួកគាត់ត្រូវបានផ្តល់ការព្យាបាលផ្សេង ដូចជាត្រួតពិនិត្យនិងព្យបាលសំអាត ធ្មេញដោយក្រុមគ្រូពេទ្យ ស្មគ្រ័ចិត្តរបស់សាលាគិលានុប្បដ្ឋាកៈខេត្តកំពង់ចាម កុំឡុងពេលនិស្សិតចុះកម្មសិក្សា។ ជាលទ្ធ

ផល សិស្សទាំងអស់ទទួលបានសុខភាពល្អប្រសើរជាងមុន បើធៀបទៅនឹងកាលពីនៅឯសហាគមន៍ របស់ពួកគាត់។

| *បញ្ហាជួបប្រទះ* | *ដំណោះស្រាយ* |
| --- | --- |
| ខ្វះជំនាញផ្តល់ប្រឹក្សាយោបល់ | គម្រោងនឹងផ្តល់ជំនាញនេះបន្ថែមដល់បុគ្គលិក |

## ៨). កម្មវិធី ថែទាំបន្ត

គិតពីចាប់ផ្តើមរហូតមកដល់ឆ្នាំ ២០១៥ សិស្សដែលបានរៀនចប់ជំនាញ ក្នុងមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ មាន៤ជំនាន់ សរុប ចំនួន ៧១ នាក់។ ផ្នែកជំនាញចុងភៅ ចំនួន៤៩% ផ្នែកកាត់ដេរ ចំនួន ៣៨% និងផ្នែកត្បាញ ចំនួន១៣% នៃចំនួន សរុប។ ពួកគាត់ទាំងនោះបាន យកជំនាញទៅ ប្រើប្រាស់ផ្សេងៗគ្នា ក្នុងចំណោមសិស្សដែលបានបញ្ចប់វគ្គទាំងអស់ ៤៨%ដែលពួកគាត់មានការធ្វើទាក់ទងនឹងមុខជំនាញដែលខ្លួនបានរៀន ចំនួន ២១% ធ្វើការខុសពីជំនាញដែលបានរៀន ១៦% ទៀតបានយកចំណេះដឹងនិងជំនាញយកទៅប្រើប្រាស់បើកអាជីវកម្មខ្លួនឯងនៅតាមសហាគមន៍ និងទីផ្សារដែលពួកគាត់បានតាំងនៅ និង១៥%ជាសិស្សរៀនចប់ជំនាញហើយអត់ការងារធ្វើ នៅតែផ្ទះរកប្រាក់ចំណូលតាមរដូវការនៃការងារកសិកម្ម។




## ៩). កម្មវិធីសហគ្រិនភាពសង្គម

BSDA បច្ចុប្បន្ន កំពុងតែដំណើរការ ភោជនីយដ្ឋានដែលមានលក់ម្ហូបអាហារខ្មែរ និងម្ហូបបរទេសសម្រាប់ភ្ញៀវជាតិ និងអន្តរជាតិ ដែលមានទីតាំងនៅ ភូមិទី១២ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ស្ថិតនៅជួរមាត់ទន្លេជាប់សណ្ឋាគារមនោរម្យ។ ក្រៅពីនេះទៀត មានផ្នែកផ្សេងៗទៀតដែលជាសហគ្រិនភាពតូចៗ និងអាចចលតបាន ដូចជា ការលក់វត្ថុអនុស្សាវរីយ៍ នៃផលិតស្នាដៃរបស់សិស្សដែល រៀនចប, ថ្នាក់ភាសាអង់គ្លេសនៅសាលាបឋមសិក្សាអង្គរ និង ក្រុមសិស្សសិល្បៈរបាំប្រពៃណី និងក្រុមភ្លេងពិណពាទ្យ ដែលអាចចេញសំដែងតាមវិធីជប់លៀង ការ និងបុណ្យផ្សេងក្នុងស្រុក និងខេត្តនានា និង



ទទួលបានកម្រៃពីការសំដែងសម្រាប់ឧបត្ថម្ភដល់សិស្សក្នុងការសិក្សារៀនសូត្រ និងជួយដល់គ្រួសារ បានទៀតផង។ រាល់ប្រាក់ចំណូលពីសហគ្រិនភាពសង្គម ត្រូវវិភាគទាន ២០%ទៅអោយអង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម យកមកប្រើប្រាស់សម្រាប់បន្តការអនុវត្ត។

## ២.១.២. គម្រោងសមាគមកម្ពុជាដើម្បីកុមារក្រៅសាលា

ក. គោលបំណង៖ កុមារតាមចិញ្ចើមថ្នល់ និងកុមាររងាយរងគ្រោះទទួលបានភាពងាយស្រួលក្នុងការទទួលការអប់រំ ព្រមទាំងគេចផុតពីការរើសអើង និងការគំរាមគំហែងផ្សេងៗ។ ជនបង្គោល

,

អ្នកពាក់ព័ន្ធ និងអាជ្ញាធរពាក់ពន្ធ័ បានពង្រឹងការយកចិត្តទុកដាក់ក្នុងការជំរុញកុមារតាមចិញ្ចើមថ្នល់ និងកុមាររងាយរងគ្រោះ ឱ្យទទួលបានសេវាអប់រំ

១. ចំនួនបុគ្គលិកសរុប ៖...៩.....នាក់ ស្រី: ៤ នាក់

គ. ទីតាំងគម្រោង ៖ ខេត្តកំពង់ចាម

ឃ. សរុបថវិកាគម្រោង ៖ ៦៤០៨៦.៩១ដុល្លា

ង. កាលបរិច្ឆេទគម្រោង ៖ខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៥

ច. សកម្មភាពអនុវត្តគម្រោង៖

### ១). កុមារ OOSC ដែលស្ថិតនៅក្រោមការគ្រប់គ្រងគម្រោង ត្រូវបានបានគាំទ្រ និង ជួយអោយពួកគាត់ អាចបញ្ចប់ការសិក្សាក្នុងកំរិតបឋមសិក្សា

| គោលបំណងនៃលទ្ធផលទី ១ | គោលដៅចង់បាន | លទ្ធផល | % |
|---|---|---|---|
| ១. កុមារ OSC បានចុះឈ្មោះនៅក្នុងប្រព័ន្ធអប់រំផ្លូវការ និងមិនអប់រំក្រៅប្រពន្ធ័ ចំនួន ៥០%ជាក្មេងស្រី។ | ២០៥ | ២១៤ | ១០៤% |
| ២. កុមារនៅតែបន្តការសិក្សា ទៅឆមាសបន្ទាប់ | ៣៥៨ | ៤៥៥ | ១២៧% |

បន្ទាប់ពីគម្រោងចាប់ផ្តើមគាំទ្រផ្តល់អាហារូបករណ៍ និងការបង្រៀនបន្ថែមក្រៅសាលានៅមណ្ឌលសប្បាយសប្បាយ ពួកគេទទួលបានចំណេះដឹងកើនឡើង ហើយវត្តមាននៅឯសាលារដ្ឋក៏បានទៀងទាត់ជាងមុន។ ក្នុងឆ្នាំ២០១៥នេះ កុមារចំនួន ២១៤នាក់( ស្រី១១) បានចូលរៀននៅក្នុងសាលា។ ហើយនៅក្នុងឆមាសទីពីរ កុមារចំនួន ១៧១នាក់( ស្រី ៩២នាក់ )បានផ្តល់អាហារូបករណ៍ រួមបញ្ចូលការគាំទ្រកុមារ ៧២នាក់ទទួលបានមូនិធិ AUPADAMA ។ សិស្សជាង ៩០៦នាក់( ស្រី ១៩) ត្រូវបានឡើងថ្នាក់ ,ជារៀងរាល់ថ្ងៃគម្រោងបានផ្តល់ការអបរំបន្ថែម នៅមណ្ឌលសប្បាយសប្បាយ និងមណ្ឌលអប្សរា ដែលមានកម្មវិធីដូចជា ភាសាខ្មែរ គណិតវិទ្យា ភាសាអង់គ្លេស របាំប្រពៃណី តន្ត្រីបុរាណ ពិណពាទ្យ និងភ្លេងប្រពៃខ្មែរ

កីឡា អនាម័យ ធ្វើលំហាត់ប្រាណ និងល្បែងប្រាជ្ញា។ ដើម្បីអោយពួកគាត់មានភាពវៃឆ្លាត និងមានជម្រើសកាន់ច្រើនសម្រាប់ពួកគេនៅពេលខាងមុខ។ ក្នុងឆ្នាំនេះផងដែរ គម្រោងបានបង្កើន ការបង្ហាត់បន្ថែមនូវតន្ត្រីបុរាណ និងប្រពៃណី បញ្ចូលសាច់ភ្លេងចូលជាមួយការរាំរបាំតាមបទនិមួយៗ ទាំងពិណពាទ្យ និងភ្លេងប្រពៃណី។ ទាំងនេះគម្រោងបានផ្តល់ឱ្យពួកគេតាមរយៈអាហារូបករណ៍ និងការអប់រំក្រៅប្រព័ន្ធ គឺក្នុងគោលបំណងដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងការអប់រំរបស់កុមារ ក្រុមគ្រួសារ និងបរិយាកាសសង្គមគ្រួសារដែលកំពុងមានការខ្វះខាតចំណេះដឹង និងផ្តល់ភាពសារៈប្រយោជន៍ដល់ពួកគាត់ ក្នុងការសិក្សា និងការអប់រំផ្សេងៗរបស់ពួកគេ។ កុមារ **OOSC** ទាំងអស់អាចទទួលបានការអប់រំល្អប្រសើរ និងទៅសាលាទៀងទាត់ដោយសាមានមជ្ឈមណ្ឌលបណ្តុះបណ្តាអប់រំក្រៅប្រពន្ធ័របស់ **BSDA** ជួយជុំរុញ និងក្រើនរំលឹកបូករូម ឪពុកម្តាយរបស់ពួកគេធ្វើការលើកទឹកចិត្តកូនរបស់ពួកគេឱ្យទៅសាលារៀនយ៉ាងទៀងទាត់ និងបង្រៀនកូនបន្ថែមនៅឯផ្ទះ។ បន្ថែមពីនេះទៀតក្រុមអ្នកស្ម័គ្រចិត្ត និងបុគ្គលិកបានផ្តល់កការអប់រំចំណេះដឹងសហាគមទាក់ទងនឹងសារៈសម្ខាន់នៃការអប់រំកុមារ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| សិស្សមួយចំនួនបានបោះបង់ និងផ្លាស់ប្តូរទីលំដោយសារតែស្ថានភាពរស់នៅ ក្នុងស្ថានភាពមិនប្រសើរ ម្យ៉ាងពួកគាត់ភាគច្រើនមិនសូវមានការអប់រំខ្ពស់។ ដោយសារភាពក្រីក្រ ធ្វើអោយមានការប្រឈមនឹងអំពើហិង្សាក្នុងគ្រួសារ រំលោភពពលកម្មកូន។ កុមារដែលចេញពីស្ថានភាពនេះពេលទៅសាលារៀនភាគច្រើនត្រូវបានគេស្តីបន្ទោសពីសំណាក់អ្នកដទៃ ដូចជាគ្រូមិត្តរួមថ្នាក់របស់ពួកគេ អំពីចំណេះដឹង ស្ថានភាពជីវភាព។ | បុគ្គលិកគហើយផ្តល់វគ្គបណ្តុះបណ្តាលចំណេះដឹងផ្នែកសហាគមន៍ ផ្តល់ការប្រឹក្សាយោបល់ដល់កុមារទាំងនោះ និងអាណាព្យាបាល ដើម្បីអោយស្វែងយល់កាន់តែស៊ីជម្រៅលើផ្នែកអប់រំដែលជាកត្តាសម្ខាន់សម្រាប់កូនៗ ឬអប់រំដើម្បីកុមារទាំងអស់គ្នា។ លើសពីនេះទៅទៀតបុគ្គលិកដែលបានជួបនាយកសាលាដើម្បីផ្តល់យោបល់ ដល់គ្រូបង្រៀនសាលាទាក់ទងសិទ្ធិកុមារ និងការរំលោភបំពានផ្សេងៗ និងការអធ្យាស្រ័យខ្ពស់សម្រាប់កុមារ។ ចំណែកបញ្ហាអំពើហិង្សាក្នុងគ្រួសារយើងបានសហការជាមួយអាជ្ញាធរមូលដ្ឋានដទៃទៀត ដើម្បីធ្វើអន្តរាគមន៍ដោយសញ្ញាចុះកិច្ចសន្យាសម្រាប់អំពើហឹង្សានៅក្នុងគ្រួសារ។ |

## គ). មណ្ឌលសំចត និងហេដ្ឋារចនាសម្ព័ន្ធត្រូវបានរៀបចំកែប្រែ និងធ្វើឱ្យប្រសើរឡើងដើម្បីអនុញ្ញាតឱ្យកុមារក្រៅសាលាបានចូលរៀន និងអប់រំបន្ថែម

នៅក្នុង ឆ្នាំ 2015 នេះគម្រោងបាន ធ្វើរបងព័ទ្ធជុំវិញមណ្ឌលសប្បាយសប្បាយ ដើម្បីការពារកុំឱ្យសត្វនិងមនុស្សផ្សេងទៀតចូលទៅខាងក្នុងដែលជាការរំខានដល់កុមារដែលកំពុងសិក្សា ,សាងសង់សួនកុមារ មានទោង បាសប៊េក ទីធ្លាខ្សាច់សម្រាប់កុមាររត់លែងសម្រាក់ពេលចេញលេង ,ហើយបានចាក់ដីបំពេញបរិវេណមណ្ឌលជៀសផុតពីការលិចទឹកធ្វើអោយបរិស្ថានស្អាត មិនមានក្លិនស្អុយ អាចផ្តល់ឱកាសអោយក្មេងរត់លេងបានពេញទីធ្លា ក្រៅពីនេះទៀត គម្រោងបានជួសជុលបន្ទប់ទឹកសម្រាប់ពួកគាត់ដើម្បីពង្រឹងផ្នែកអនាម័យ។ នៅមណ្ឌលមួយទៀតគឺ មណ្ឌអប្សរាដែលមានទីតាំងនៅក្រោយប្រាសាទអង្គរ ក៏

ជាមជ្ឈមណ្ឌលមួយផ្តល់ការអប់រំក្រៅប្រពន្ធ័ផងដែរ មានរបាំប្រពៃណី ភ្លេងបុរាណ ចំណេះដឹងទូទៅ និង ជាកន្លែងសម្រាប់ភ្ញៀវទេសចរណ៍ចូលមកទស្សនាសិល្បៈបុរាណ របស់គម្រោង កុមារមេគង្គកម្ពុជា ការ អនុវត្តន៍សកម្មភាពនៅមណ្ឌលទាំងពីរខាងលើ គាំទ្រដោយ អង្គការ EcoSolidar, Aid et Action, Rustic Pathways, AUPADAMA Foundation។ ជាលទ្ធផលទទួលបាន សិស្សតូចៗ 171 កុមារ( ស្រី 100 នាក់) ដែលកំពុងសិក្សានៅក្នុងមជ្ឈមណ្ឌលទាំងនេះ។ ចុងឆ្នាំនេះចំនួនកុមារបានកើន ឡើងជាបន្តបន្ទាប់ ដោយសារយើងបានពង្រីកតំបន់គោលដៅថ្មីហើយអាណាព្យាបាលមានការយល់ដឹង ពីសារៈសំខាន់ កាន់តែច្រើនហើយបញ្ជូនកូនអោយមករៀននៅមណ្ឌលរបស់អង្គការ។ ជារៀងរាល់ថ្ងៃរាល់កុមារទាំង អស់ត្រូវបានអង្គការជូនទៅមកដោយរឺម៉កកង់បី ពីភូមិទៅកាន់មណ្ឌល ហើយលើសពីនេះទៀត កុមារត្រូវ បានផ្តល់កម្លាំងចិត្តបន្ថែ និងជាការជុំរុញអោយពួកគាត់មានការចូលរួម គឺអង្គការបានផ្តល់ អាហារសម្រន់ មាននំនិងទឹកជាដឹម ក្នុងអំឡុងពេលសិក្សារបស់ពួកគេ នៅក្នុងមណ្ឌល។ នៅក្នុងមណ្ឌលទាំនោះ មានគ្រូ បឋមសិក្សាប្រចាំវេ ទាំងពេព្រឹក និងពេលល្ងាច ហើយមានព្រះសង្ឃ មួយអង្គផងដែរ សម្រាប់ការផ្តល់ការ អប់រំសីលធម៌ ក៏ដូចជាបង្រៀនចំណេះដឹងផ្សេងៗទៀតដែរ។ យោងតាម លទ្ធផលនៃការប្រឡងរបស់ សិស្សនៅ មណ្ឌលសប្បាយសប្បាយ បានបង្ហាញថា 32% នៃសិស្សដែលសម្រេចបានក្នុងកម្រិតល្អ, 23% គឺជាកម្រិតសមស្រប 38% នៅកម្រិតមធ្យមនិង 7% គឺជាកម្រិតខ្សោយ។

## ខ). គ្រូបង្រៀននិងអ្នកបណ្តុះបណ្តាលមានឆន្ទៈនិងអាចផ្តល់នូវការអប់រំដល់កុមារ OOSC ទាំងអស់

យុទ្ធនាការស្តីពីការប្រកាសអោយកុមារគ្រប់អាយុ អោយចុះឈ្មោះចូលរៀនបាន រួមមានភូមិ បឹង បាសាក់, អំពិលលើ, តាណោង និងភូមិអណ្តូងច្រុះ ដែលបានការសហការជាមួយអាជ្ញាធរភូមិ និងបឋម សិក្សាចំនួនបួន។ នេះជាការជោគជ័យមួយដែលទទួលបានការូលរួម ពីអ្នកពាក់ពន្ធ័ ដែលបានជួយរៀបចំ ប្រតិបត្តិការ មុនពេលពិធីបើកបវេសនកាល។ យុទ្ធនាការនេះបានដង្ហែរក្បួនដើរតាមដងវិថី របស់សាលា គោលដៅនិមួយៗ ជាអទិភាពនៃទីតាំងដែលមានកុមារចូលរួមក្នុងយុទ្ធនាការនេះមាន 326 កុមារ (កុមារី 187), អាជ្ញាធរប៉ុស្តិ៍នគរបាលគ្រូបង្រៀន 63 នាក់( ស្រី៣៧ នាក់) ។ គម្រោងនេះមានគោលបំណង ដើម្បី ផ្តល់ពត៌មានដល់សហគមន៍ ជាពិសេសឪពុកម្តាយដែលមានកូនគ្រប់អាយុអោយចូលរៀន តែមិនបាន យល់ដឹង ឬប្រងើយកន្តើយចំពោះកូន អំពីការចុះឈ្មោះចូលរៀនដោយរវាល់គិតពីរកស៊ី។ បន្ទាប់ពីការធ្វើ យុទ្ធនាការនេះមកសង្កេតឃើញថា កុមារមួយចំនួនបានកើនឡើងយ៉ាងខ្លាំងតាមសាលាគួរអោយកត់ស ម្គាល់។

## គ). កុមារ OOSC និងក្រុមគ្រួសារត្រូវបានកំណត់អត្តសញ្ញាណ និងផ្តល់ការយល់ដឹងអំពីសារៈសំខាន់នៃការអប់រំ

សម្រាប់សកម្មភាពនេះគម្រោងមិនមានថវិការសម្រាប់អនុវត្តន៍ទេ ប៉ុន្តែបុគ្គលិកចាំបាច់ត្រូវធ្វើការសហការជាមួយនាយកសាលាដើម្បីអោយដំណើរការកម្មវិធី។ ហើយនេះជាឆ្នាំដំបូង, សាលានិមួយៗមិនសូវបានធ្វើផែនសាលា ដូច្នេះសកម្មភាពនេះត្រូវរងចាំថវិការទើបដំណើរការ។

### ឃ). កុមារ OSC ចូលរៀនបឋមសិក្សា

| លទ្ធផល ឃ | គោលដៅចង់បាន | លទ្ធផល | % |
|---|---|---|---|
| ១. ចំនួនអាហារូបករណ៍ដែលបានផ្តល់ទៅអោយកុមារ **OSC** ទៅតាមលក្ខណ្ឌ(អោយជាប្រាក់ ឬ អាហារូបត្ថម្ភ) | ៧៥ | ១៧១ | ២៣១% |

ចុងឆ្នាំ ២០១៥, គម្រោងនៅតែបន្តការផ្តល់អាហារូបករណ៍ដល់កុមារ រហូតដល់ ១៧១នាក់ (ស្រី ៩២)ដែលជាកុមារក្រីក្រីរស់នៅក្នុងស្ថានភាពលំបាកហើយសុទ្ធតែជាប្រភពគ្រួសារក្រីក្រនិងចំណាកស្រុកមកពីស្រុកផ្សេងមករស់នៅក្រុងកំពង់ចាម។ ពួកគេត្រូវបានជ្រើសរើសទៅតាមលក្ខណ្ឌឬរបស់គម្រោងបានកំណត់ ជាពិសេសកុមារក្រីក្រី និងកុមារក្រៅសាលាជាអាទិភាព។ បន្ទាប់ពីបានជ្រើសរើសរួចមកពួកគាត់ត្រូវបានធ្វើការនែនាំពីគោលនយោបាយ និងកិច្ចសន្យាការទទួលកញ្ចប់អាហារូបករណ៍ ប្រសិនបើពួកគាត់មិនគោរពតាមកិច្ចសន្យា ពួកគាត់ត្រូវបានបញ្ឈប់។ នៅចុងឆ្នាំនេះគម្រោងបានកុងត្រា សិស្សអាហារូបករណ៍ ចំនួន ១៦១នាក់ (ស្រី៨៣នាក់)។ សិស្សទាំងអស់ត្រូវទទួលបាន អង្គករ ២៣គក, ប្រេងឆា ១លីត, ស្ករ១គក, អំបិលអ៊ីយ៉ូត កន្លះគក, ទឹកត្រី១ដប, ទឹកស៊ីអ៊ីវ១ដប និងត្រីខ១កំប៉ុង ស្មើរនឹងទឹកប្រាក់ ១៥ ដុល្លារសហរដ្ឋអាមេរិច ជារៀងរាល់ខែ។ ក្រៅពីនេះ គម្រោងបានផ្តល់សម្ភារៈសិក្សាដល់សិស្សទាំងអស់ក្នុងម្នាក់ទទួលបាន សៀវភៅ ប៊ិច ខ្មៅដៃ បន្ទាត់ ជ័រលប់ កាប៉ូក មួយចប់ និងសំលៀកបំពាក់១កំផ្លេ ម្តងក្នុងមួយឆ្នាំ ដូចគម្រោង កុមារមេគង្គកម្ពុជាដែរ។ អាហារូបករណ៍នេះទទួលបានជំនួយពី អង្គការ Aid et Action, AUPADAMA and Rustic Pathways។

## ២). គុណភាពការអប់រំត្រូវបានពង្រឹង

| លទ្ធផល ទី២ | គោលដៅចង់បាន | លទ្ធផល | % |
|---|---|---|---|
| ១. ចំនួនគ្រូដែលបានអនុវត្តតាមនិយាមគរុកោសល្យ ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំ និងកុមារ បរិយាកាសមិត្តភាពសម្រាប់ OSC ។ | ១៥ | ១០ | ៦៦.៦៦ % |
| ២.ការអប់រំរបស់សិស្សត្រូវបានពង្រឹង | | | |
| ក).កុមារ **OOSC** បានបញ្ចប់កំរិតបឋម ហើយបានបង្ហាញនិងការនែនាំនឹងឈានចូលថ្នាក់អនុវិទ្យាល័យ | ២៥ | ៣០ | ១២០% |
| ខ).អត្រាឡើងថ្នាក់ក្នុងមួយឆ្នាំ | ៣៦៨ | ៤០៦ | ១១០% |
| គ).អត្រាត្រួតថ្នាក់ក្នុងមួយឆ្នាំ | ៤៩ | ១២ | ២៤% |

| | | | |
|---|---|---|---|
| ឃ).អត្រាបោះបង់ | ៤៩ | ១៨ | ៣៧% |

គម្រោងនេះបានប្តល់វគ្គបណ្តុះបណ្តាលស្តីពីនិយាមគរុកោសល្យ និងបច្ចេកទេសផ្សេងៗដែលទាក់ទងទៅនឹងការពង្រឹងលើវិស័យអប់រំ។ ហើយវគ្គបណ្តុះបណ្តាលនេះគឺធ្វើឡើង អស់រយៈពេល២ថ្ងៃ មានអ្នកចូលរួមលោកគ្រូ អ្នកគ្រូ១៥នាក់ មកពីសាលាតំបន់គោលដៅរបស់គម្រោងក្នុងស្រុកកំពង់សៀម និងស្រុកកំពង់ចាម ក្រោមប្រធានបទ (ពង្រឹងគុណភាពនៃការបង្រៀន និងវិធីសាស្ត្រ ល្បែងសិក្សា និងវិធីសាស្ត្រថ្មី ដើម្បីគាំទ្រដល់ការបង្រៀនរបស់គ្រូកាន់តែមានគុណភាពខ្ពស់។ ជាមួយគ្នានេះដែរបុគ្គលិកបាន ពាំនាំយកនូវវិធីសាស្ត្ររបស់ អង្គការមិត្តសំឡាញ់ដែលជាអង្គការ មានជំនាញ និងមានបទពិសោធន៍ក្នុង ការបង្រៀនកុមារតាមចិញ្ចើមផ្លូវ និងកុមារក្រៅសាលា ថែមទាំងផ្តល់ជាឯកសារការលេងហ្គេមដើម្បី សាលារៀន មកបង្រៀនដល់គ្រូៗ ក្នុងគោលបំណងដើម្បីឱ្យដឹងថាតើវិធីសាស្ត្រថ្មីទាំងនេះអាចអនុវត្តបាន ល្អកម្រិតណា ហើយពួកគាត់អាចយកទៅអនុវត្តបានប៉ុន្មានភាគរយ។ ក្នុងកំឡុងពេល សិក្ខាសាលាបណ្តុះបណ្តានេះផងដែពួកគេ មើលទៅមានភាពសប្បាយរីករាយ និងបានចូលរួមយ៉ាងសកម្ម ព្រមទាំអបំផុស គំនិតផ្សេងៗធ្វើអង្គពីទាំងមូលមានភាពសកម្ម និងជោគជ័យគួរអោយកត់សំគាល់។ ពួកគាត់បានប្តេជ្ញាចិត្ត អនុវត្តវិធីសាស្ត្រនេះ នៅតាមសាលារៀនគោលដៅរៀងៗខ្លួន។

ក្រោយពីសិក្ខាសាលចប់ ក្រុមការងារបានបន្តការចុះតាមដាននិងត្រួតពីនិត្យបានបញ្ជាក់ឃើញថា ៦៦%នៃសិក្ខាកាម បានអនុវត្តបច្ចេកទេសពីវគ្គសិក្ខាសលានេះ និង៤៤%ទើតែចាប់ផ្តើមអនុវត្តដោយសារ មានភាពមាញឹកការងារសាលាមួយចំនួនពុំទាន់បានបញ្ចប់។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| -ខ្វះថវិការសម្រាបទិញសម្ភារៈល្បែងសិក្សា ជាហេតុធ្វើអោយការបណ្តុះបណ្តាល មិនបានគ្រប់សាលាគោលដៅ។<br>-គ្រូដែលបានទទួលសម្ភារៈពីអង្គការពួកគាត់មិនទាន់អាចអនុវត្តបានក្នុងថ្នាក់រៀនរបស់ពួកគាត់។ | -ជម្រុញអោយគ្រូប្រើប្រាស់សម្ភារៈ ឬធនធានសិក្សាដែលមានស្រាប់ មកប្រើប្រាស់ទាំងនៅក្នុងសហគមន៍ និងសាលាមកប្រើប្រាស់ក្នុងការអប់រំ។ |

### គ).ឧបករណ៍អប់រំគឺសាកសមទៅនឹងតម្រូវការរបស់កុមារ OOSC (សកម្មភាពមិនទាន់បានអនុវត្តន៍)

### ខ).តួនាទីរបស់គ្រូបង្រៀនជាអ្នកពង្រឹង និងធ្វើអោយប្រសើរឡើងដល់កុមារ OOSC ទាំងអស់

| លទ្ធផល ខ | គោលដៅចង់បាន | លទ្ធផល | % |
|---|---|---|---|
| ១. ចំនួនគ្រូដែលបានចូលរួមវគ្គបណ្តុះបណ្តាល ដើម្បីកែលំអនិងផ្តលវិធីសាស្ត្រការបង្រៀនតាមទម្រង់ជាក់លា | ១៥ | ១៨ | ១២០% |

| | | | |
|---|---|---|---|
| ក់។ | | | |

កំឡុងពេលរបាយការណ៍ ក្រុមការងារគម្រោងបានសហការជាមួយសាលាគោលដៅ និងអង្គការមិត្តសំឡាញ់ ជាអ្នកគាំទ្របច្ចេកទេស ដើម្បីផ្តល់ការបណ្តុះបណ្តាលស្តីពីឧបករណ៍នៃល្បែងសិក្សារយៈពេល ២ ថ្ងៃ។ ក្នុងវគ្គនេះមានអ្នកចូលរួម ១៨នាក់ (ស្រី១៧) និងបុគ្គលិ ៨នាក់ រៀនអំពីរបៀបបង្រៀន ជាភាសាខ្មែរ , គណិត និងវិធីសាស្ត្រល្បែងសិក្សាថ្មីៗ វគ្គនេះដែរ ពួកគាត់មានការចាប់អារម្មណ៍ រំពឹកទុកច្រើនលើវិធីសាស្ត្របែបនេះ ហើយពួកគាត់សន្យា និងយកទៅអនុវត្តសម្រាប់ឆ្នាំក្រោយៗទៀត។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| សម្ភារៈល្បែង និងឧបករណ៍សិក្សាសម្រាប់គ្រូ មានតម្លៃថ្លៃ ម្យ៉ាងគម្រោងមិនសូវមានថវិការ | ប្រធានគ្រប់គ្រងគម្រោងរាយការណ៍ សំណើរ បូរប្រទានទៅថ្នាក់គ្រប់គ្រង។ គម្រោង ព្យាយាមស្វែរកថវិការបន្ថែមសម្រាប់ទិញសម្ភារៈនេះ |

**គ).គណៈគ្រប់គ្រងសាលាត្រូវធ្វើឱ្យប្រសើរឡើងដើម្បីផ្តល់នូវសេវាកម្មអប់រំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានប្រសិទ្ធភាព (សកម្មភាពមិនទាន់អនុវត្ត)**

**៣). មេដឹកនាំអប់រំ / អ្នកផ្តល់សេវាត្រូវមានតួនាទីយ៉ាងសំខាន់ដើម្បីកែលម្អការអប់រំប្រកបដោយប្រសិទ្ធិភាព:**

**ក). SSCsចូលរួមយ៉ាងសកម្មក្នុងការងារលើកកម្ពស់ការចុះឈ្មោះចូលរៀន និងការគ្រប់គ្រងសាលារៀន (សកម្មភាពមិនទាន់អនុវត្ត)**

**ខ). អជ្ញាធរក្នុងតំបនដាក់បញ្ចូល កុមារ OSC ចូលក្នុង CDP (សកម្មភាពមិនទាន់អនុវត្ត)**

**គ).មន្ទីរអប់រំ ខេត្តនិង ស្រុក ធានាឱ្យបាននូវការតាមដានប្រកបដោយប្រសិទ្ធភាព និង ផ្តល់ការណែនាំដើម្បីគាំទ្រដល់ការ កុមារ OSC។(សកម្មភាពមិនទាន់អនុវត្ត)**

**ឃ).ឪពុកម្តាយបានចូលរួមក្នុងសកម្មភាពអប់រំរបស់កូនៗ**

| លទ្ធផល ឃ | គោលដៅចង់បាន | លទ្ធផល | % |
|---|---|---|---|
| ១. ចំនួនអាណាព្យាបាលយល់ដឹង និងចូលប្រជុំសកម្មភាពសាលា ស្តីពីបំនិនជីវិតសាលារបស់កុមារ និង | ១១៧ | ១៧១ | ១៤៦.១៥% |

| | | | |
|---|---|---|---|
| សកម្មភាពក្រុមមាតាបិតា។ | | | |

ហេតុផលដែលសុចនាករទីមួយ បានសម្រេចលើសការរំពឹងទុក ដោយសារគម្រោងបានសម្រេចចិត្តផ្តល់ចំណេះដឹងភ្លាមខណៈពេលយើងបានរកឃើញចំនុចខ្សោយ ដូចជាការយល់ដឹងរបស់របស់ឪពុកម្តាយមិនទាន់បានយល់ច្បាស់ពីបំនិនជីវិតសាលារបស់កុមារ និងសកម្មភាពក្រុមមាតាបិតាជាមួយនឹងសាលា។ ចំពោះសូចនាករ (ខ)មូលហេតុថាសុចានករ (ក) និង(ខ) មិនទាន់បានអនុវត្តនៅឡើយទេដោយសារតែគោលដៅមានផែនការសម្រាប់ឆមាស និងឆ្នាំក្រោយទៀត ដូច្នេះសម្រាប់ឆមាសឆ្នាំនេះគឺមានផែនការទាំងនេះទេ រួមទាំងថវិកាសម្រាប់អនុវត្តផងដែរ។

### ខ).គ្រួសារបានធ្វើឱ្យប្រសើរឡើងនូវជីវភាព

ដើម្បីទំនុកបំរុងដល់កូនរបស់ពួកគេអោយបានទៅសាលារៀន សកម្មភាពនេះ គឺធ្វើការរៀបចំកិច្ចតែងការបង្រៀន បង្រៀនដល់ក្រុមគ្រួសាររបស់សិស្សអាហារូបករណ៍ ពីការគ្រប់គ្រងប្រាក់ចំណូល និងផែនការទីផ្សារ។ គ្រួសារដែលអាចទទួលវគ្គបណ្តុះបណ្តាលបាន លុះត្រាត្រូវតាមលក្ខណ្ឌរបស់គម្រោង។ ចំពោះគ្រួសារដែលមានអាជីវកម្មចលត័ស្រាប់ ឬពួកគាត់មានដើមទុននិងសម្ភារៈ ឬតូបស្រាប់ហើយនោះហើយជាគ្រួសារក្រីក្រ និងមានកូនច្រើន ត្រូវបានជ្រើសរើស។ ដោយឡែកសកម្មដែលបានរៀបរាប់នេះ ពុំទាន់បានអនុវត្តនៅឡើយទេ គឺចាប់ផ្តើមនៅឆ្នាំថ្មីនេះ។

## ៤). បរិស្ថានអប់រំត្រូវបានធ្វើឱ្យប្រសើរឡើងតាមរយៈការគស៊ូមតិនិងការស្រាវជ្រាវ

### ក).សហគមន៍មានការយល់ដឹងអំពីសារៈសំខាន់នៃការធ្វើសមាហរណកម្មកុមារ OOSC បញ្ចូលក្នុងជីវិតសហគមន៍ បានប្រសើរជាងមុន

| លទ្ធផល ក | គោលដៅចង់បាន | លទ្ធផល | % |
|---|---|---|---|
| ១. ចំនួននៃសមាជិកសហគមន៍រួមចំណែកក្នុងយុទ្ធនាការលើកកម្ពស់ការយល់ដឹងស្តីពីសារៈសំខាន់នៃការធ្វើសមាហរណកម្មកុមារ OSC បញ្ចូលក្នុងជីវិតសហគមន៍ | ៧៤ | ១៧១ | ១៨៦.១៥ % |

សម្រាប់រយៈពេលប្រាំមួយខែចុងក្រោយនេះ, ក្រុមគ្រួសាររបស់កុមារត្រូវបានផ្តល់វគ្គបណ្តុះបណ្តាលការយល់ដឹងក្នុងសង្គមជារៀងរាល់សប្តាហ៍ដោយក្រុមបុគ្គលិកសហគមន៍ ផ្តល់បាន ៦ វគ្គដែលមាន ២៨៣ នាក់ (ស្រី ១៩៧នាក់) ក្នុងនោះកុមារ ៤៨ (ស្រី: ៣) ដែលអញ្ជើញមកពីសហគមន៍ចំនួន២០ និង ១៧១ គ្រួសារ មានមាតាបិតា ប្រធានភូមិ និងកុមារ បង្រៀន១ដងក្នុងមួយសប្តាហ៍ ក្រោមប្រធានបទ អំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពាន គ្រឿងញៀន ការធ្វើចំណាកស្រុក សិទ្ធិកុមារ ការជួញដូរកុមារ ការអប់រំជាមូលដ្ឋាន។ តាមការអង្កេតឃើថា សហគមន៍មានការយល់ដឹងពីសារៈសំខាន់នៃការសិក្សារបស់កូ

នៗ ពួកគេ និងដឹងផ្លាស់ប្តូរពីទំលាប់ការរស់នៅមិនសូវមានរបៀប ទៅជាទំលាប់ល្អ ហើយចេះគិតពីអនាម័យ និងចេះជួយលើកទឹកចិត្តដល់កូនៗច្រើនជាងមុន។

### ខ).មន្ទីរអប់រំស្រុកនិងខេត្តបានប្តេជ្ញាចិត្តដាក់បញ្ចូលកុមារ OSC ក្នុងកម្មវិធីអប់រំ

សម្រាប់រយៈពេលប្រាំមួយខែនេះបុគ្គលិកគម្រោងបានសហការយ៉ាងល្អជាមួយ PoE, DoE និងនាយកសាលា ដើម្បីដាក់ដំណោះស្រាយបញ្ហានៅតាមសាលារៀនគោលដៅទាំងអស់ ដោយជួយបង្រៀនក្រៅម៉ោងបន្ថែម ក្នុងការលើកទឹកចិត្តកុមារ អោយទទួលបានការសិក្សាល្អប្រសើរជាងមុន។ ជាលទ្ធផលកុមារដែលចង់រៀនហើយពួកគេបានចូលរួមក្នុងគ្រប់សកម្មភាពរបស់គម្រោងនិងសាលាសាធារណៈរបស់ខ្លួន។ ក្រុមកុមារទាំងអស់ចូលចិត្តរៀនទាំងពីរផ្នែក ទាំងនៅសាលា និងក្នុងមណ្ឌលអង្គការ។ Poe, DoE បានដោះស្រាយបញ្ហាដោយជោគជ័យនឹងលើកឡើងនូវបញ្ហាជាប្រចាំត្រីមាសដើម្បីដោះស្រាយ នៅពេលប្រជុំម្តងៗ។

## ៥). បញ្ហាប្រឈម និងយុទ្ធសាស្ត្រ

ក). សម្រាបមូលនិធិបដិភាគរបស់ BSDA ជាមួយគម្រោងនេះ ត្រូវការបន្ថែម ដើម្បីគាំទ្រដល់អាហារូបករណ៍ ៥៥០ សិស្ស/គ្រួសារ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះ BSDA មានគម្រោងផែនការធ្វើការជាមួយនឹងគម្រោង GlobeMed ផ្តល់ជំនួយពីសហរដ្ឋអាមេរិកដើម្បីបដិភាគចូលគម្រោង។ មួយទៀតអ្នកគ្រប់គ្រងគៀងគរថវិការ នឹងស្វែងរកការគាំទ្រពី មូលនិធីរបស់ក្រុមហ៊ុន Rustic Pathways មកពីសហរដ្ឋអាមេរិក និងភ្នាក់ងារក្សៀរទេសចរផ្សេងៗទៀត។

ខ). បញ្ហាប្រឈមផ្សេងទៀតគឺកុមារនៅតែបន្តការបោះបង់ការសិក្សា, គម្រោងសូម្បីតែបានផ្តល់អាហារូបករណ៍ផ្តល់ការប្រឹក្សានិងការលើកទឹកចិត្តពួកគេក៏ដោយ។ នេះដោយសារតែវានៅតែតម្រូវការចំណាយច្រើនសម្រាប់គ្រួសាររបស់ពួកគេ ដូច្នេះពួកគេត្រូវធ្វើចំណាកស្រុក ឬទៅធ្វើការស៊ីឈ្នួលតាមផ្ទះស្រុក និងខេត្តផ្សេងទៀត។ ក្រៅពីនេះទៀត កុមារ OSC គឺកំព្រាឪពុកម្តាយ ដែលបានស្លាប់ និងរត់ចោលនិងទុកអោយនៅជាមួយជីដូនកន្ទោចកន្ទែង ជាហេតុសម្រេចចិត្តបោះបង់សាលា។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះគម្រោងនឹងព្យាយាមស្វែងរកមូលនិធិបន្ថែមទៀត ដើម្បីផ្គត់ផ្គង់បន្ថែម និងរកវិធីសាស្ត្រធ្វើអោយគ្រួសារអាចរកប្រាក់ចំណូលបានតាមរយៈការអភិវឌ្ឍន៍ជីវភាពសហគមន៍ របស់អង្គការ BSDA, ដូច្នេះពួកគេនឹងមិនផ្លាស់ទៅខេត្តផ្សេងទៀតនិងកុមារអាចទៅសាលារៀនបាន។

គ). ឪពុកម្តាយមួយចំនួនបង្ខំកូនរបស់ពួកគេរកប្រាក់នៅលើចិញ្ចើមផ្លូវដែលជាសកម្មភាពមួយ បន្ទុចបង្អាការទៅសាលារៀន ដោយសារតែឪពុកម្តាយឈ្លក់វង្វេងនឹង ល្បែងស៊ីសងស្រា ជំពាក់បំណុល។ នេះជាបញ្ហាពិតៗ ដែលកក្រុមការងារបានជួបប្រទះ ហើយក៏បានសហការជាមួយអាជ្ញាធរ និងអ្នកពាក់ពន្ធដើម្បីជួយដោះស្រាយបញ្ហានេះ ប៉ុន្តែវានៅតែមានកើតឡើងដដែលៗ ទោះបីបុគ្គលិកគម្រោងខិតខំ ផ្តល់ប្រឹក្សាដោយផ្ទាល់នៅតែមានកើតឡើង តែក្រុមការងារនៅតែបន្ត នឹងរកយុទ្ធសាស្ត្រថ្មីបន្ថែមទៀត និង

សហការជាមួយអាជ្ញាធរអោយបានទៀងទាត់ ដើម្បីទប់ស្កាត់ កុំអោយកើតមានយ៉ាងហោចណាស់ក៏បាន កាត់បន្ថយមួយភាគធំដែរ។

### ៦). មេរៀនបទពិសោធន៍ និងការបង្កើតថ្មី

#### - មេរៀនបទពិសោធន៍

បន្ទាប់ពីការអនុវត្តគម្រោងរយៈពេល ៦ ខែចុងក្រោយនេះ យើងទទួលបានបទពិសោធន៍ល្អមួយ ក្នុងការបញ្ចុះបញ្ចូលគ្រួសាររបស់កុមារដែលមិនបានបញ្ជូនកូនរបស់ពួកគេអោយទៅសាលា អោយដើរសុំទាន ដើម្បីយកប្រាក់ជួយគ្រួសារ ហើយបន្ទុចបង្អាក់មិនអោយកូនបានទៅសាលា ម្យ៉ាងទៀត កូននេះមិនមានបញ្ជីសំបុត្រកំណើតទៀត។ បញ្ហានេះបុគ្គលិក បានព្យាយាម ចុះជួបពួកគាត់ផ្ទាល់ ហើយធ្វើអន្តរាគមន៍បញ្ចុះបញ្ចូល បន្ទាប់មកពួកគាត់បានយល់ព្រមអោយកូនទៅសាលា និងបញ្ឈប់កូន អោយទៅសុំទាន ទោះបីពុំមានសំបុត្រកំណើត ក៏ដោយសាលារៀនបានអនុញ្ញាតិអោយក្មេងនេះបានចូលរៀនដែរ ឯកសារនឹងធ្វើនៅតាមក្រោយ។

#### - ការបង្កើតថ្មី

តាមរយៈសកម្មភាពគម្រោងបានផ្តល់ការអប់រំបំណុះបណ្តាលបន្ថែម ដោយទទួលក្មេងមក ពីសហគមន៍ ក្នុងក្រុងកំពង់ចាម មករៀននៅមណ្ឌលសប្បាយសប្បាយ។ និងមណ្ឌលមួយកន្លែងទៀត គឺមជ្ឈមណ្ឌលអប្សរាដែលស្ថិតនៅខាងលិចប្រាសាទបុរាណ អង្គរបាជ័យ ក៏ជាមណ្ឌលបណ្តុះ បណ្តាលក្រៅប្រពន្ធ័ និងមានកុមារជាច្រើនមកពីសហគមន៍ជុំវិញវត្តនរគបាជ័យ ក្នុង ស្រុកកំពង់សៀម។

### ២.១.៣. គម្រោងការអប់រំជាមូលដ្ឋាន

*ក. គោលបំណង៖* ពង្រឹងការអប់រំនូវមូលដ្ឋានកំរិតបឋម

| | |
|---|---|
| *ខ. ចំនួនបុគ្គលិកសរុប* | ៖៦ នាក់ ស្រី: ២ នាក់ |
| *គ. ទីតាំងគម្រោង* | ៖ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តកោះកុង |
| *ឃ. សរុបថវិកាគម្រោង* | ៖179,051.00 ដុល្លា |
| *ង. កាលបរិច្ឆេទគម្រោង* | ៖ខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៥ |

*ច. សកម្មភាពអនុវត្តគម្រោង៖*

### ១).ដោយចុងបញ្ចប់នៃឆ្នាំ ២០១៨ ការគាំទ្រសាលារៀនរបស់អង្គការ BSDA ដែលទទួលមូនិធិ ពីអង្គការសង្គ្រោះកុមារអន្តរជាតិ សម្រេចបាននូវលទ្ធផលល្អប្រសើរជាងមុននៅក្នុង ការរៀនសូត្រអក្សរខ្មែរ

សាលាគ្រូ បានបង្កើតសកម្មភាពសប្បាយប្បាយ ភ្ជាប់ជាមួយមេរៀនសាលា និងបំនិនជីវិត ដើម្បីទាក់ទាញក្មេងអោយមានការចូលរួម។ ហើយសិស្ស ក៏អាចយកពេលវេលាសម្រាក់ទៅអានសៀវភៅនៅក្នុងបណ្ណាល័យនិងសាលាកម្រង ហើយសិក្សាជាក្រុមដើម្បីទទួលបានចំណេះដឹងបន្ថែម។ ក្រៅពីនោះ

កុមារងាយគ្រោះ និងកុមារពិការភាពត្រូវបានយកចិត្តទុកដាក់ និងថៃទាំជាខ្លាំង នៅក្នុងថ្នាក់រៀនត្រូវផ្តល់កន្លែងជាពិសេសសម្រាប់ពួកគាត់។ ក្រៅពីសកម្មភាពរៀនក្នុងសាលា, មានកុមារ៩ក្លឹបនៅតាមសហគមន៍បានបង្កើតឡើង ហើយបានបំពេញត្រឹមត្រូវតាមគោលការណ៍ ចំនួន កុមារ២០៩នាក់ ចាប់ពីថ្នាក់ទី ២ ដល់ថ្នាក់ទី ៦ ក្នុង ៩សាលាបឋម។ បន្ទាប់ពីម៉ោងសិក្សាពួកគេ ចំណាយពេល ២ម៉ោងដើម្បីចូលរួមសិក្សាជាក្លឹប ហើយបង្កើតកម្មវិធីសប្បាយ បូករួមនឹងការអានជាមួយ មិត្តភក្តិផងគ្នា។ សិស្សធំ ជួយបង្រៀនសិស្សតូច ឬអ្នកចេះបង្រៀនអ្នករៀនយឺត ឬខ្សោយ។ ជំនួយនេះគឺ ជំរុញអោយកុមារមានការផ្សារភ្ជាប់សាលាទៅនឹង សហគមន៍។ ក្មេងៗមានសប្បាយរីករាយចំពោះគម្រោងនេះដែលធ្វើអោយ សហគមន៍ គ្រូ និងឪពុកម្តាយ មានឱកាសបន្ថែម ការអភិវឌ្ឍន៍ចំណេះដឹងរបស់ពួកគេ ក៏ដូចជាការជួយគ្នាទៅវិញទៅមកដូចជា បង្រៀនជាដើម។ បន្ថែមពីនេះទៀតពួកគេមានទំនុកចិត្តជាក់លាក់ជាមួយគ្រូ និងអណាព្យាបាលរបស់ពួកគាត់តែងតែជំរុញ និងគាំទ្រលើការសិក្សា។

### ក).បង្កើនការចូលរួមរបស់កុមារដើម្បីអោយតម្លៃ ការបោះពុម្ពសៀវភៅ និងឯកសារផ្សេងៗ ទាំងក្នុង និងក្រៅសាលា៖

គម្រោង PS បានអនុវត្តន៍ សិក្ខាសាលស្តីពី ការប្រមែប្រមូលសម្ភារៈការអាន ដើម្បីប្រាប់ដល់អ្នកចូលរួម ទទួលបាននូវមធ្យោបាយនៃឧបករណ៍អាន ដែលមាននៅក្នុងសហគមន៍ និងកន្លែងផ្សេងទៀត។ នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល ៩៥% ដែលយល់ច្បាស់ពីមេរៀន។ គម្រោងបានផ្តល់ផងដែរនូវ សម្ភារៈសិក្សាអនក្ខរកម្ម (សៀវភៅអំណាន ចំនួន៧៦៨ក្បាល) ផ្តល់ទៅអោយ បណ្ណាល័យ ៧សាលា បឋមសិក្សា ។ សម្ភារៈទាំងអស់មាន ធ្នើដាក់សៀវភៅ ២៦, ក្តារខៀនពិណខ្មៅ ២៤, ឡាំងដែក ២១, តង់កៅស៊ូ និងល្បែងអនក្ខរកម្មជាច្រើនឈុត និង ក្តារខៀនសសម្រាប់គ្រូ ចំនួន ៣៣០, ត្រូវបានផ្តល់ ទៅសលាក្រុមគោលដៅ ចំនួន ២១សាលាក្នុងខេត្តពោធិសាត្វ។ រាល់សកម្មភាពទាំងអស់ ផ្តោត់ទៅលើផលវិបាកនៃការអានអក្សរ និងការសេរបូករួមនឹងសកម្មភាពផ្លែកៗទៀត ដើម្បីលើកកំពស់ការអប់រំ។ គម្រោងត្រូវតែសហការរវាងកម្រោង និងសហគមន៍ដើម្បីបង្កើនធនធានដែលមានស្រាប់នៅក្នុង សហគមន៍។ ក្រៅពីនេះ វគ្គបណ្តុះបណ្តាលបានផ្តោតទៅលើសម្ភារៈអាន មានដូចជា៖

១) កំណត់ធនធានសហគមន៍

២) វិធីសាស្រ្ត និងដំណើរការនៃសិក្សាក្លិប

៣) ការគ្រប់គ្រងនិងការត្រួតពិនិត្យ

ជាការពិតតាមការត្រួតពិនិត្យឃើញថា បានកើនឡើងដល់ 80% ក្រោយការធ្វើតេស្តប្រៀបធៀបទៅ 40% នៃការវាយតំលៃ មុនការធ្វើតេស្ត។ ការរៀនសូត្រសមរម្យនិងប្រើសម្ភារត្រូវបានគេផ្តល់ទៅឱ្យសាលារៀន 21 (Tiroumkhet, ស្នាច់មានជ័យយ, សម្តេចជាស៊ីមកោះ Kapi ជ្រោយប្រុសកោះ Sralao, វត្ត Trapangroung កោះកុង Knung, ប៉ាក់ឃ្លាំង, បឹង Kachhang, Mandalsima កោះកុង, បឹង Preav ព្រៃកស្ទឹង Angkorphnomklung, ទ្រាក Chipat, កោះស្តេច Tamkan, Tanoun និង Chamkarler) ។

## ១).គ្រូបង្រៀនដែលមានសមត្ថភាពចាំបាច់និងការលើកទឹកចិត្តក្នុងការបង្រៀនអក្ខរកម្ម និងផ្តល់ការបង្រៀនបន្ថែម និងការគាំទ្រដល់កុមារ ទាំងអស់ រួមទាំងការរៀនសូត្រនិងការអភិវឌ្ឍដែលមានតម្រូវការខុសគ្នា ។

តាមរយៈការសហាការដ៏ល្អជាមួយដៃគូរ ដែលមាន PoE, DoE,សាលារៀន និងអាជ្ញាធរក្នុងស្រុក។ យើងបានទទួលលទ្ធផលលើសពីអ្វីដែលបានរំពឹងទុករបស់គម្រោង។ មានអ្នកចូលរួម ១១២នាក់ ស្រី ៨០នាក់ ដែលអញ្ជើញមកពី PTTC, 8 DoEs និង ២៦នាក់ មកពីសាលាគោលដៅ បានចូលរួមសិក្ខាសាលាស្តីអំពី វិធីសាស្រ្តនៃការបង្រៀននៅថ្នាក់ទី ១, ទី២ និងទី៣។ ជាមូលលដ្ឋានផ្តោតទៅលើរបៀបធ្វើផែនការបង្រៀនប្រកបដោយប្រសិទ្ធិភាពរួមទាំងសៀវភៅអំណាន, បទដ្ឋាន ឬតាមសុចនាករដែលបានកំណត់ ហើយអោយសមតុល្យទៅនឹងគោលបំណងរបស់សិស្ស។ ដើម្បីឆ្លើយតបទៅនឹងលទ្ធផលរបស់ក្មេង គម្រោងបានបដិភាគសម្ភារៈសិក្សាកុមារតូចចំនួន ២៦ឈុតទៅអោយ ២៦សាលាបឋមសិក្សានៅតាមគោលដៅ។

## ២). នៅចុងឆ្នាំ ២០១៨អង្គការសង្គ្រោះកុមារអន្តរជាតិនឹងជួយគាំទ្រហូតដល់ ៣០០ សាលារៀន

តាមរយៈការសហាការបានល្អ ការប្រជុំ សិក្ខាសាលា និងវគ្គបណ្តុំបណ្តាលជាមួយដៃគូរ ព្រមទាំងមន្ទីរអប់រំ, ការិយាល័យអប់រំ, គណកម្មការទ្រទ្រង់សាលា,មណ្ឌលសុខភាព និងអាជ្ញាធរ។ ជាលទ្ធផលកំពុងនឹងជំរុញ អោយមានសុខភាពអនាម័យនៅតាមសាលា គ្មានអំពើហឹង្សា នឹងស្របតាមវិន័យសាលា។ មានក្មេងប្រហែល៧៩៧០នាក់ បានចូលរៀនថ្នាក់ទីមួយ នៅក្នុងឆ្នាំនេះ ស្មើរនឹង ៤៧.១%ជាក្មេងស្រី។ គណកម្មការទ្រទ្រង់សាលាបានដឹងពីទំនួលខុសត្រូវរបស់ពួកគាត់ ធ្វើការងារសាលាឃុំ និងនូវកំរិតសាលាផ្សេងៗគ្នាដូចជា ផ្នែកគ្រោះមហន្តរាយធម្មជាតិ គណនេយ្យភាពសង្គម ការឃោសនា និងការកសាងសមត្ថភាពស្តារនីតិសម្បទាកុមាររងាយរងគ្រោះ, ការការពារកុមារ, អធិការកិច្ច និងជំរុញ ការត្រួតពិនិត្យនិងការលើកទឹកចិត្ត, ការគ្រប់គ្រងស្ថិតិ, ការគ្រប់គ្រងក្លិបកុមារសុខភាពនិងហេដ្ឋារចនាសម្ព័ន្ធ...

សិក្ខាសាលាបានធ្វើឡើងក្រោមប្រធានបទ ការអប់រំប្រកបដោយវិជ្ជមាន បានបង្ហាញថា សាលាមានតួនាទីត្រឹមតែ ៤យ៉ាងប៉ុណ្ណោះ គឺះ

១) រាងកាយនិងផ្លូវចិត្តត្រូវការជាចាំបាច់ (ការសន្ទនារវាងគ្រូនិងសិស្ស) ។

២) អនាម័យសម្រាប់សុខភាព (ការចោលសំរាមការបរិភោគអាហារនិងយកទឹក)

៣)ការរៀបចំឯកសារនិងការធ្វើផែនការការងារ (សរសេរនិងអនុវត្តសកម្មភាពជីវិតប្រចាំថ្ងៃ)

4. ការគាំទ្រការរៀនរបស់សិស្សនិស្សិតស្ថិតនៅក្នុងបញ្ហា (ភាសាខ្មែរនិង គណិតវិទ្យា) ។

## ក) ពង្រឹងយន្តការសាលារៀនសម្រាប់ទទួលនិងឆ្លើយតបនៅនឹងពាក្យបណ្តឹង

ដើម្បីសម្រេចបាននូវគោលដៅរបស់គម្រោង ការព្យាយាមដើម្បីលុបបំបាត់ការរើសអើង

អំពើហិង្សា ការបំភិតបំភ័យ, ការគំរាមកំហែងនិងការឃោឃីនិងរបៀបបៀនកេរ្តិ៍ ។ យើងបានជជែកទៅកាន់គ្រូបង្រៀន ចំនួន ៣២នាក់ គណកម្មការទ្រទ្រង់សាលា ២៨នាក់ និងសមាជិកក្រុមប្រឹក្សាឃុំ ជាគណៈកម្មាធិសម្រាប់ស្ត្រីនិងកុមារ (CCWC) ។ សិក្ខាសាលានេះត្រូវបានផ្តោតលើគោលបំណងសំខាន់ចម្បង៣គឺ៖

១)ច្បាប់ក្រមសីលធម៌របស់គ្រូក្នុងការបង្រៀន

២)យន្តការរាយការណ៍ពីសិស្ស ថ្នាក់រៀន និងសាលា

៣)យន្តការឆ្លើយតបនិងអន្តរាគមន៍ដើម្បីធ្វើឱ្យប្រសើរឡើងផែនការ

បន្ទាប់ពីសិក្ខាសាលាបញ្ចប់ វាបានបង្ហាញឃើញថា ២០%នៃ ២១សាសាដែលមានយន្តការ ការត្រួតពិនិត្យគម្រោងនិងសាលាកម្រងដើម្បីជាការកត់សំគាល់/កត់ត្រ និងទទួលត្រូវរាល់ពាក្យបណ្ដឹងតវ៉ា។ ដើម្បីឆ្លើយតបទៅនឹងរឿងទាំងនោះ គម្រោងបានផ្តល់សម្ភារៈមួយចំនួន និងលើកកំពស់ការយល់ឃើញ ត្រូវដើម្បីធ្វើ អោយសាំចំពោះ សិស្សានុសិស្ស គ្រូបង្រៀន មាតាបិតា អាណាព្យាបាល និងសមាជិកសហ គមន៍។

## ខ) ការផ្តល់កញ្ចប់បទដ្ឋានអប្បបរិមានៃសេវាសុខភាពរបស់សិស្ស

គម្រោងអប់រំរបស់ពួកយើង មានបំណងដើម្បីពង្រឹងសុខភាពអនាម័យសិស្ស តាមរយៈ អនាម័យទឹកស្អាត ថ្នាំទម្លាក់ព្រូន, សកម្មភាពរាងកាយ, សុខភាពមាត់ធ្មេញនិងភ្នែក។ ជាការពិតណាស់, គម្រោងបានផ្តល់កម្មវិធីសាលាដើម្បីសុខភាពដល់អ្នកចូលរួមចំនួន ៦៦នាក់មកពីសាលាចំនួន ២៦។ សាលាបានសហការដោយផ្ទាល់ជាមួយនឹងមណ្ឌលសុខភាព ដែលជាអ្នកធ្វើអន្តរាគមន៍ដើម្បីរៀបកញ្ចប់សុខភាពនៅ តាមសាលារៀន មាន គ្រែ កន្ទេល សម្ភារៈសង្គ្រោះបឋម... និងផ្តល់ដំបូន្មានដល់បុគ្គលិកដែលពាក់ពន្ធ ទៅនឹងបញ្ហាកើតឡើងជាយថាហេតុផ្តោតទៅលើបរិស្ថានសុវត្ថិភាព ការអប់រំសុខភាពនិងសេវា។

## គ) សាលា និងមន្ទីរអប់រំត្រូវមានទិន្នន័យជាក់លាក់ដើម្បីចាត់ជាអទិភាព និងកំណត់ផែនការសាលា

បុគ្គលិកគម្រោងអប់រំបានសហការជាមួយមន្ត្រីអប់រំ ដើម្បីការពង្រឹងប្រព័ន្ធស្ថិតិនិងពត៌មាន ដើម្បីធានាថាទិន្នន័យទាំងអស់ត្រូវបានរក្សាទុក និងបានរៀបចំទុកដាក់តាមផ្នែក ថ្នាក់ ឆ្នាំនិមួយៗ សកម្មភាពនេះក៏ជាការជំរុញការគ្រប់គ្រងផែនការសាលារៀន។ សាលារៀនចំនួន ២១ សាលាទទួលបាន សម្ភារៈ EMIS សម្រាប់ទុកដាក់ និងរក្សាសម្រាប់ទិន្នន័យរបស់ពួកគេ។

## ឃ) ពង្រឹងសមត្ថភាពមន្ត្រីអប់រំខេត្តនិងស្រុក ដើម្បីគាំទ្រការពង្រឹងការអភិវឌ្ឍន៍ផែនការសាលា

យើងបានសហការជាមួយអង្គការសង្គ្រោះកុមារអន្តរជាតិ ហើយមន្ត្រីអប់រំខេត្ត ក្នុងការផ្តល់នូវគុណភាពបរិស្ថានសិក្សា (QLE) ដល់សិក្ខាកាមចំនួន ៦០ នាក់មកពីសាលារៀនគោលដៅ ចំនួន ២៦សាលា។ អ្នកចូលរួមបណ្តុះបណ្តាលបានសន្មត់គោលការណ៍ QLE ដូចជាការគាំទ្រកម្មវិធីអប់រំ៖

១) បំពេញតាមតម្រូវការផ្លូវអារម្មណ៍និងផ្លូវចិត្តរបស់សិស្ស។

២) ការពារសុខុមាលភាពផ្លូវកាយរបស់កុមារ។

៣) ជំរុញនិងគាំទ្រដល់ការចូលរួមយ៉ាងសកម្មសម្រាប់សិស្សានុស្ស ការបង្រៀនសិស្សជាក្រុម និង រៀនពីលទ្ធផលសម្រេច ពីអ្នកសិក្សា។

៤) ឪពុកម្តាយនិងសហគមន៍មូលដ្ឋានដែលត្រូវបានចូលរួមយ៉ាងសកម្មក្នុងការធ្វើផែនការ និងការសម្រេចចិត្ត ឥទ្ធិពលសកម្មភាពនៃការអភិវឌ្ឍ សាលារៀននិងសាលាកុមារមេត្រី (CFS) ។

## ៣). មេរៀនបទពិសោធន៍

-តាមរយៈអនុវត្តគម្រោង ក្នុងអំឡុងពេលរបាយការណ៍ បុគ្គលិកគម្រោងទទួលបាន សមិទ្ធិផលជាច្រើន គួរឱ្យកត់សម្គាល់ និងត្រៀមធ្វើអន្តរាគមន៍សម្រាបមេរៀនខាងមុខផងដែរ។ បុគ្គលិកគម្រោងអប់រំធ្វើកិច្ចសហប្រតិបត្តិការ និងសហការជាមួយអ្នកជំនាញទាំងអស់ ស្ថាប័នពាក់ព័ន្ធការគាំទ្រពីគ្រូបង្រៀន ព្រមទាំងសហគមន៍ ដើម្បីដំណើរការ សកម្មភាពរបស់ខ្លួនយ៉ាងមានភាពរលូន។

-គ្រូបង្រៀននៅថ្នាក់ទី 1 ទី 2 និងទី 3 ត្រូវបានអនុវត្តតាមចំណេះដឹងនិងបទពិសោធន៍របស់ពួកគេធ្វើអោយមានភាពងាយស្រួលជាងមុន ជាមួយនឹងសម្ភារៈ និងវិធីសាស្រ្តដែលទទួលបាន។ វាជាការពិតអ្វីដែលមានការផ្លាស់ប្តូរ ហើយថ្មីគួរអោយទាក់ទាញ ជាពិសេសគំនិតច្នៃប្រឌិតថ្មី វិធីសាស្រ្តថ្មី ធ្វើអោយសិស្សមានអារម្មណ៍ និងចូលចិត្តសិក្សា ហើយទៅសាលារៀនបានទៀងទាត់។ ហើយគម្រោងនៅតែរក្សាសកម្មភាពនេះដើម្បីធ្វើអោយសកម្មភាពកាន់តែមានដំណើរការល្អ។

-បង្កើតវិធីប្រពៃណីដើម្បីស្វែងយល់ថា ជាវប្បធម៌នៃការអប់រំមួយដើម្បីឱ្យប្រាកដថា កុមារទាំងអស់អាចអានសរសេរនិយាយនិងទទួលបានបំណិនជីវិតជារៀងរហូត។ លើសពីនេះទៀត, វាមិនត្រឹមតែបង្កើនកម្មវិធីអក្ខរកម្មប៉ុណ្ណោះទេ ថែមទាំងបានផែនការបង្រៀនប្រកបដោយគុណភាព និង បង្កើនបរិស្ថានសិក្សាអោយបានល្អប្រសើរជាងមុន នៅលើកម្រិតមួយដែលអាចទទួលយកបាន។

## ៤). បញ្ហាប្រឈម

-កង្វះការគាំទ្របច្ចេកទេសក្នុងការអនុវត្តគម្រោង ពិបាកក្នុងការប្រមូលទិន្នន័យក្នុងអំឡុងពេលរដូវកាលធ្វើរបាយការណ៍ មានន័យថាឧបករណ៍ដែលសម្រាប់ធ្វើរបាយការណ៍គឺជា ជាទម្រង់បែបសាលារៀន school form គឺបែបនេះប្រមូលមិនបានល្អប្រសើរ។

-ពីខែកក្កដាដល់ខែធ្នូឆ្នាំ 2015 បានដកស្រង់សម្ដីបញ្ហាប្រឈមនៅលើប្រាំចំណុចៈ ការផ្លាស់ប្តូរអាកាសធាតុ លើផ្ទៃសមុទ្រ និងតាម ក្នុជ្រលងភ្នំខ្ពង់រាប មានរលក ខ្យល ដែលជាបញ្ហាសម្រាប់សិស្សមួយចំនួនអាកខានមិនបានទៅសាលារៀនទៀងទាត់ ក្នុងខេត្តកោះកុង។

-នៅតំបន់ដាច់ស្រយាលរបស់គោលដៅគម្រោង គ្មានម ភ្លើងអគ្គីសនី ដើម្បីដំណើរការការងារបច្ចេកទេសកុំព្យូទ័របញ្ចាំងស្លាយ នៃការធ្វើបទបង្ហា និងកម្មវិធីផ្សេងៗសម្រាប់គម្រោង

-ពីបាកប្រមូលទិន្នន័យពីមន្ទីរអប់រំ ដើម្បីសរសេររបាយការណ៍ ។

## ២.២-កម្មវិធីសុខភាព

### ២.២.១-បង្ការ ការថែទាំ និងការគាំទ្រ អ្នករស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍ នៅតាមសហគមន៍

*ក.គោលបំណង* ដើម្បីកាត់បន្ថយពីផលប៉ះពាល់នៃមេរោគអេដស៍/ជំងឺអេដស៍ក្នុង ចំណោម

អ្នករស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងនូវសុខភាពរបស់ពួកគាត់ និង គុណភាពជីវិត ។

ខ. ចំនួនបុគ្គលិកសរុប ៖.៩..នាក់ ស្រី: ៥ នាក់

*គ. ទីតាំងគម្រោង* ៖ ខេត្តកំពង់ចាម និតខេត្តត្បូងឃ្មុំ

*ឃ. សរុបថវិកាគម្រោង* ៖ 103550.5ដុល្លា

*ង. កាលបរិច្ឆេទគម្រោង* ៖ខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៥

*ច. សកម្មភាពអនុវត្តគម្រោង៖*

### ១).ការរួមបញ្ចូលសេដ្ឋកិច្ចគ្រួសារ និងការបណ្តុះបណ្តាលជំនាញ

-សកកម្មភាពនេះ បានធ្វើសមាហារណកម្ម ៧០គ្រួសារ ក្នុងខេត្តត្បូងឃ្មុំ។

### ២). ពង្រឹងសមត្ថភាពស្ថាប័ន

### ក. កិច្ចប្រជុំជាមួយបុគ្គលិក និងCSV

កិច្ចប្រជុំប្រចាំត្រីមាសជាមួយបុគ្គលិក និង អ្នកស្មគ្រ័ចិត្តគាំទ្រសហគមន៍ បានបញ្ចូលទិន្នន័យចូលក្នុងប្រពន្ធ័ត្រួតពិនិត្យនិងវាយតម្លៃ និងប្រើប្រាសឧបករណ៍ប្រមូលទិន្នន័យ។ ពួកគាត់បានយល់ដឹង ពីរបៀបបញ្ជូន អ្នកផ្ទុកជំងឺអេដស៍ទៅរកសេវាសុខភាព, និងការភ្ជាប់បណ្តាញជាមួយអ្នកពាក់ពន្ធ័ រួមទាំងចេះដោះស្រាយបញ្ហាពេលកើតមានកំឡុងពេលអនុវត្តន៍។ ក្រុមការងារបានប្រជុំបុគ្គលិកប្រចាំខែ បាន ២ ដងនៅឯការិយាល័យ BSDA ពីការធ្វើបច្ចុប្បន្នភាពរបាយការតាមផ្នែកនិមួយៗរបស់អង្គការ និងប្រធានបទទាក់ទងទៅនឹងការចែករំលែកចំណេះដឹងផ្សេងៗទៀតដល់បុគ្គលិកទាំងអស់។ និងប្រជុំ ជាមួយអ្នក ស្មគ្រ័ចិត្តគាំទ្រសហគមន៍បានចំនួន២ដងលើប្រធានបទ ការបែងចែកតួនាទីនៅតាម សហគមន៍ និងការរៀបចំឯកសារការងារចុះសហគមន៍ ជាលទ្ធផលពួកគត់បានយល់ដឹង កាន់តែច្បាស់ ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនក្នុងកិច្ចការ ស្មគ្រ័ចិត្តបំរើសហគមន៍ និងទទួលបាននូវវិធីសាស្រ្ត សម្រប់សម្រួលបញ្ជូនសេវា ជួយប្រឹក្សាយោបល់ ចង់ក្រងក្រុមបណ្តាញ និងរបៀបចុះតាមដានអ្នកជម្ងឺ។

### ខ. ការកសាងសមត្ថភាព/ កិច្ចប្រជុំក្រុមការងារបច្ចេកទេស/ សិក្ខាសាលា

ការចូលរួមប្រជុំក្រុមការងារបច្ចេកទេស ជាកិច្ចប្រជុំប្រចាំខែជាមួយ មន្ទីរសុខាភិបាលខេត្ត កំពង់ចាមបានចំនួន២លើក ស្តីពីព្រឹត្តិការណ៍ប្រយុទ្ធប្រឆាំងនិងមេរោគអេដស៍/ជម្ងឺអេដស៍ និងការបែង ចែក

តំបន់គោលដៅនិមួយៗសម្រាប់អង្គការក្នុងខេត្តទទួលខុសត្រូវតាមសាម៉ីអង្គការ ដើម្បីកុំអោយ សមាជិកអង្គការធ្វើការ ត្រួតតំបន់គោលដៅគ្នា,ក្រៅពីនេះទៀត ក្រុមការងារបាន ចូលរួមប្រជុំ ស្រុកប្រតិបត្តិ ស្រីសន្ធរ ព្រៃឈរ។ នៅខេត្តត្បូងឃ្មុំប្រជុំបាន ៩ដង កឺស្រុកប្រតិបត្តិពញាក្រែក ត្បូងឃ្មុំ និងអូររាំងឪ ដែលជជែកពី សេវាសុខភាពប្រចាំមន្ទីរពេទ្យបង្អែកនិមួយៗ និងដំណោះស្រាយ រាល់បញ្ហា ក្រុមគោលដៅដែលអង្គការបានបញ្ជូន។

## គ. ការតាមដាន និងការត្រួតពិនិត្យ

ប្រធានកម្មវិធីរបស់អង្គការ បានចុះធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃការងារកម្មវិធី អេដស៍ និងអ្នកទទួលផល ដើម្បីធ្វើអោយច្បាស់ថា ការអនុវត្តន៍ គម្រោងត្រូវបានដើរទៅតាម ផែនការដែលបានកំណត់ឬក៏គម្លាតយ៉ាងណា ហើយក៏បានចុះទៅទស្សនកិច្ចគម្រោង មួយទៀតនៅ ខេត្តត្បូងឃ្មុំ។

## ឃ. កិច្ចសម្របសម្រួល និងការសហការណ៍

នៅចុងឆមាសនេះបុគ្គលិកគម្រោងបានធ្វើការសហការជាមួយពាក់ពន្ធ័ចំនួន ៩ដង ចូលរួមព្រឹត្តិការណ៍ប្រយុទ្ធប្រឆាំងនិងមេរោគអេដស៍/ជម្ងឺអេដស៍ ចំនួន ២ដង មន្ទីរសុខាភិបាល ចំនួន៣ដង និងស្រុកប្រតិបត្តិ ចំនួន ៩ដង។

## ង. ព្រឹត្តិការណ៍ និងវេទិកាផ្សេងៗ

ក្រុមថ្នាក់ដឹកនាំ BSDA មានលោកនាយកប្រតិបត្តិ នាយកកម្មវិធី ក្រុមបុគ្គលិកផ្នែកសុខភាព បានចូលរួមព្រឹត្តិការណ៍ប្រយុទ្ធប្រឆាំងនិងមេរោគអេដស៍/ជម្ងឺអេដស៍ ចំនួន ២ដង គឺនៅខេត្តកំពង់ចាមម្តង និងនៅខេត្តត្បូងឃ្មុំម្តង។ សម្រាប់ព្រិត្តិការណ៍នៅខេត្តកំពង់ចាម មានអ្នកចូលរួម ចំនួន ៥០០នាក់ (ស្រី៣០០នាក់)។ បានរៀបចំយុទ្ធនាការស្វែងយល់ពីមេរោគអេដស៍/ជម្ងឺអេដស៍,ពួកគាត់ បានយល់ច្បាស់ពីរបៀបការពារជម្ងឺឆ្លង និងយុទ្ធនាការមួយទៀតឺការការពារតាមរយ: ការប្រើប្រាស់ស្រោម អនាម័យ និងមានភាពស្មោះត្រង់ជាមួដៃគូរ ហើយត្រូវនិយាយថាទេ ជាំមួយថ្នាំញៀនជាមួយអ្នកដទៃទៀត។

## ៣). យែនឌ័រ (ការបណ្តុះបណ្តាល, ការប្រជុំ SHG, អំពើហឹង្សាទាក់ទិននឹងយែនឌ័រ និង ព្រឹត្តិការណ៍ផ្សេងៗ

កិច្ចប្រជុំប្រចាំត្រីមាសជាមួយបុគ្គលិក និង អ្នកស្មគ្រ័ចិត្តគាំទ្រសហគមន៍ ស្តីពីការបញ្ចូលទិន្នន័យចូលក្នុងប្រពន្ធ័ត្រួតពិនិត្យនិងវាយតម្លៃ និងប្រើប្រាសឧបករណ៍សម្រាប់ប្រមូលទិន្នន័យ។

## ៤). ការថែទាំ និងគាំទ្រសម្រាប់អ្នកផ្ទុកមេរោគអេដស៍

### ក). ពន្លឿនការស្វែងរកករណីមេរោគអេដស៍

ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ (HTC) ក្នុងចំណោម ប្តីប្រពន្ធដែលដៃគូម្ខាងមានផ្ទុកមេរោគអេដស៍ (Zero-discordant couple) អ្នកដែលគួរឱ្យសង្ស័យដទៃទៀត។ នៅចុងឆ្នាំនេះមាន ១៧ គូស្វាមីភរិយាជា Zero-discordant couple។ បុគ្គលិកគាំទ្រសហគមន៍ និងបុគ្គលិកស្មគ្រ័ចិត្ត បានជំរុញអោយដៃគូរផ្សេងទៀតដែលមិនផ្ទុកមេរោគ ប្រើសេវាធ្វើតេស្តឈាម(HTC) ក្នុងចំណោមដៃគូរម្នាក់ទៀត។ សម្រាប់សេវានេះ មិនបានបញ្ជូនទៅទេ ព្រោះនៅក្នុងត្រីមាសនេះមានពេលវាលាតិចសម្រាប់ការអនុវត្តកម្មវិធី ម្យ៉ាងទៀតគម្រោងទើបតែចាប់ផ្តើមទំលាក់ថវិកាអោយអនុវត្តចាប់ ពី ថ្ងៃទី ១៥ ខែ វិច្ឆិការ ២០១៥ រហូតដល់ ៣១ ធ្នូរ ២០១៥។

ក្រុមបុគ្គលិកបានបានធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងប្រធានភូមិនិងប្រធានមណ្ឌលសុខភាព ដើម្បីលើកទឹកចិត្តដល់ ស្ត្រីមានផ្ទៃពោះទូទៅ អោយទៅរកសេវាតេស្តឈាមរកមេរោគអេដស៍ នៅមណ្ឌលសុខភាព។ លទ្ធផលការធ្វើតេស្តរបស់ពួកគេគឺ វិជ្ជមាន ហើយពួកគេអាចតាមដានសុខភាពផ្ទៃពោះ របស់ពួកគេ នៅពេលដែលពួកគេបានជួបអ្នកផ្តល់ប្រឹក្សាឬគិនុប្បដ្ឋាយិក។ ក្រៅពីក្រុមគោលដៅខាងលើ, CSVs បានសង្ស័យ និងសំដៅលើអ្នកជំងឺរបេង ក៏ជំរុញនិងបញ្ជូនពួកគាត់អោយទទួលសេវាតេស្តឈាម ក្នុងចំណោ ២នាក់ លទ្ធផលគឺ 0 លទ្ធផលវិជ្ជមាន។

### ខ). ពង្រឹងការបន្តការថែទាំជារអតិបរមា

បុគ្គលិកបានចុះដឹកនាំប្រជុំក្រុមជួយខ្លួនឯង និង-ការចុះសួរសុខទុក្ខតាមផ្ទះដើម្បីផ្តល់ដំណឹងជួយតាមចំពោះការជំរុញអោយទទួលបានសេវា Pre-ART/ART និងការតាមដាន (រួមទាំងចំនួនអ្នកផ្ទុកមេរោគអេដស៍ពេញសិទ្ធិដែលទទួលបានសេវា ART, ចំនួនអ្នកផ្ទុកមេរោគអេដស៍ពេញសិទ្ធិដែលមិនទាន់ទទួលបានសេវា ART, CD4 និង Viral Load) ។

ជាលទ្ធផលគម្រោងមានក្រុមអ្នករស់នៅជាមួយមេរោគអេដស៍ PLHIVs ចំនួន ២០២០នាក់ (ស្រី ១១៣១) ១៩៩២នាក់បានទទួលសេវា ART និង ២៨នាក់ ទទួលសេវា Pre-ART។ ៣៧៧ ករណី(ស្រី ២៥៤) បានទទួលសេវា Pre-ART/ART, ចំណែកកុមារគ្មាន។ ហើយ ៩ករណីស្រីទាំងអស់បានទទួលសេវា STI និង ៥ករណី (ស្រី៤) បានទទួលសេវា TB។ អង្គការបានផ្សារភ្ជាប់ប្រព័ន្ធបញ្ជូនរវាងសហគមន៍ និងកន្លែងផ្តល់សេវា Pre-ART/ART ហើយពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអ្នកផ្តល់សេវា ផ្តល់ពត៌មាន និងទទួលពត៌មានរបស់អ្នកជម្ងឺតាមរយៈលោកគ្រូពេទ្យ ពាក់ពន្ធ័នឹងការផ្លាសប្តូរទីលំនៅអ្នកជម្ងឺ ហើយបាត់បង់ការតាមដានសុខភាពពីគ្រូពេទ្យ។

### គ). ការរួមបញ្ចូលសុខភាពផ្លូវភេទនិងបន្តពូជ ការបង្ការការចម្លងពីម្តាយទៅកូន និងសុខភាពមាតា និងទារក

បុគ្គលិកបានផ្តល់ចំណេះដឹងពី SRH/FP, PMTCT ទៅក្រុមអ្នកស្មគ្រចិត្ត និងអ្នកចូលរួមសរុបទាំងអស់ ៤២២នាក់ (ស្រី២៧៦)

### ឃ). បញ្ហាប្រឈម

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| -មិនសូវមានអ្នកជំងឺមកចូលរួមប្រជុំក្រុមជួយខ្លួនឯង ដោយសារពួកគាត់ជាប់រវល់និងការងារផ្សេង ៗ ។<br>-ក្រុមគោលដៅPLHIVមានការចំណាកស្រុកទៅរកស៊ីនៅខេត្តផ្សេង(ក្រចេះនិងមេមត់ជាដើម) ។<br>-អ្នកជំងឺបាត់ការតាមដាន ។<br>-ការអនុវត្តកម្មវិធីមានរយៈខ្លី។ | ចុះតាមដាននិងសួរសុខទុក្ខអ្នកជំងឺតាមផ្ទះ។<br>ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន។ |

### ង). បទពិសោធន៍ដែលបានរៀនសូត្រកន្លងមក

ការផ្តល់របាយការណ៍ប្រចាំត្រីដល់អាជ្ញាធរ និងអ្នកពាក់ព័ន្ធ ជាសកម្មភាពសំខាន់ និងជាវិធី សាស្រ្តប្រសើរបំផុតក្នុងការពង្រឹងទំនាក់ទំនង ការគាំទ្រ និងកិច្ចសហាការក្នុងការអនុវត្តសកម្មភាពការងារ ។ ការជំរុញឱ្យបុគ្គលិកចូលរួមប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ ដូចជា CoC , Stakeholder meeting, Pro-TWGH and OD ជាវិធីសាស្រ្តក្នុងការពង្រឹងសមត្ថភាព និងកិច្ចសហប្រតិបត្តិការ។

## ២.២.២ - គម្រោងការធ្វើអោយប្រសើរឡើងនូវជីវភាព (PLI)

*ក. គោលបំណង៖*ការបង្កើនជីវភាពសហគមន៍អ្នកផ្ទុកមេរោគអេដស៍ជម្ងឺអេដស៍ និងបង្កើនអាហារូបត្ថម្ភ អាហាររូបត្ថម្ភ, ការធ្វើផែនការគ្រួសារ ការកាត់បន្ថយការមាក់ងាយសហគមន៍ ការអនុវត្តឱកាសសម្រាប់ភាពជាអ្នកដឹកនាំសហគមន៍និងកសាងជីវភាពរស់នៅ

*ខ. ចំនួនបុគ្គលិកសរុប* ៖..១......នាក់ ស្រី: 0 នាក់

*គ. ទីតាំងគម្រោង* ៖ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ

*ឃ. សរុបថវិកាគម្រោង* ៖.៧៥០០.ដុល្លា

*ង. កាលបរិច្ឆេទគម្រោង* ៖ខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៥

*ច. សកម្មភាពអនុវត្តគម្រោង៖*

### ១). ផ្តល់ការបណ្តុះបណ្តាល ផ្នែកចិញ្ចឹមមាន់ និងផ្តល់ប្រាក់កំចី មុនពេលដែលយើងបានផ្តល់នូវប្រាក់កម្ចី

សមាជិកម្នាក់ត្រូវលចូលរួមការបណ្តុះបណ្តាការមួយវគ្គ។អ្នកទទួលផលត្រូវយល់ដឹងអំពីអនាម័យ បរិស្ថាន សុខភាពនិងចាក់ថ្នាំបង្ការ, ការបែងចែកចំណាត់ថ្នាក់មាន់ ដែលមានអាយុ និងមាឌខុសគ្នាដាក់ដោយឡែក និងពិនិត្យមើល តម្លៃនៅលើទីផ្សារតាររដូវកាលនិមួយៗ ដើម្បីអោយច្បាស់ថាអាចនាំចូលក្នុងទីផ្សារបាន។

ការផ្តល់ប្រាក់កម្ចីសម្រាប់ឆ្នាំ 2015 ត្រូវបានបញ្ចប់នៅក្នុងខែមិថុនារួចរាល់ហើយ។ ចំណែក១៨ គ្រួសារទៀតដែលស្ថិតនៅក្នុងស្រុក អូររាំងឪ និងស្រុកពញាក្រែកទទួលបានប្រាក់ម្ចី 120.00$ ។ ជាជំហានដំបូងនៃដើមខែមិថុនាពួកគេទទួលបាន 60 $ ដើម្បីទិញសម្ភារសម្រាប់ ទ្រុងមាន់។ លើកទីពីឬ ពួកគាត់ទទួលបាន ៦០ដុល្លាទៀតយកទៅទិញពូជមាន់មកចិញ្ចឹម ទិញចំណី និងថ្នាំបង្ការ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| អ្នកទទួលផលមួយចំនួនមិនទាន់បានចូលរួមវគ្គបណ្តុះបណ្តាលពេញលេញ ដូច្នេះធ្វើអោយពួកគាត់មានចំណេះដឹងមិនគ្រប់គ្រាន់ សម្រាប់ការងារនេះ។ | បុគ្គលិកចុះសហគមន៍ ដើម្បីពន្យល់ពួកគាត់អំពីហានិភ័យនៃការចិញ្ចឹមមាន់ |

### ២). ចុះត្រួតពិនិត្យ និងបង្រៀនការចិញ្ចឹម

គ្រួសារនិមួយៗត្រូវបានចុះត្រួតពិនិត្យមួយខែម្តង មន្ត្រីគម្រោងបានត្រួតពិនិត្យនូវប្រាក់ចំណូល និងការចំណាយផ្នែកមុខរបរចិញ្ចឹមមាន់ ហើយក៏បានបង្រៀនបន្ថែមពីបច្ចេកទេសនៃការថែរក្សា និងការចិញ្ចឹមមាន់ ការជួសជុលថែទាំទ្រុងមាន់ និងការចុះស្រង់តម្លៃទីផ្សារ។

| *បញ្ហាជួបប្រទះ* | *ដំណោះស្រាយ* |
|---|---|
| អ្នកទទួលផលមួយចំនួនមិនទាន់មានទំនុកចិត្តទៅលើរបៀបនៃការផ្តល់ចំណី និងថែទាំមាន់ | បុគ្គលិត្រូវផ្តល់ពីររបៀបការផ្តល់ចំណី គឺទៅតាមអាយុរបស់មាន់ អនាម័យ សំអាតទ្រុង និងដាក់ទឹកអោយមាន់ផឹងទៀតពេល។ |

### ៣). បង្កើតប្រាក់ចំណូលតាមរយៈការលក់ និងបង្វិលប្រាក់កម្ចីនៃការចិញ្ចឹមមាន់

គ្រួសារទាំងអស់អាចបង្វិលប្រាក់កម្ចីមកអង្គការវិញជាតាមខែដែលបានកំណត់។ពួកគាត់បានលក់មាន់ ពីរដងក្នុងមួយឆ្នាំ ទទួលបានប្រាក់ចំណូលប្រមាណ ពី ៥០០,០០០៛ ទៅ ៧០០,០០០៛។ បន្ទាប់ពីពួកគេបានលក់ហើយម្តង បានបង្វិលប្រាក់ទៅអង្គការវិញ ហើយខ្លះនៅបន្តការស្នើរសុំ ប្រាក់កំចីថ្មីម្តងទៀត ។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| ពេលលក់មាន់ៗចុះថ្លៃ | បុគ្គលិកសហគមន៍ និងជំរុញពួកគាត់លក់មាន់ នៅរដូវកាលដែលគេត្រូវការ ដូចជារដូវកាលថ្ងៃឈប់សម្រាក់ បុណ្យជាតិ ធំៗរបស់ខ្មែរ ឬចិន ទើបបានថ្លៃ។ |
| អ្នកទទួលផល ៥គ្រួសារមិនមានលទ្ធភាពបង្វិលប្រាក់កម្ចីវិញបាន។ | បុគ្គលិកផ្តល់យោបល់ និងអនុញ្ញាតអោយពួកគាត់បង់តាមលទ្ធភាពដែលមាន មិនចាំបាច់តាមតារាងកំណត់ឡើយ តែយ៉ាងហើចបានជារៀងរាល់ខែ ទោះបីតិចក៏ដោយ។ |

## ៤). ការប្រជុំប្រចាំខែជាមួយ អ្នកសន្សំប្រាក់



ការប្រជុំប្រចាំខែត្រូវបានធ្វើ នៅស្រុកអូររាំងឪ និងពញាក្រែក។ វាមានសារៈសម្ខាន់ចំពោះសមាជិកដែលពួកគេអាចជួយគ្នាទៅវិញទៅមក ដោយអោយខ្ចីលុយក្នុងសមាជិកក្រុមរបស់ពួកគាត់ ចំណែកាការកត់ត្រា និងត្រួតពិនិត្យគឺបុគ្គលិកជាអ្នកជួយសម្របសម្រួល។ កំឡុងពេលប្រជុំសមាជិកក្រុមបានប្រមូលប្រាក់កំចីមកវិញតាម កិច្ចសន្យាដែលបានចែង។

| បញ្ហាជួបប្រទះ | ដំណោះស្រាយ |
|---|---|
| ក្រុមសមាជិកប្រាក់សន្សំមិនមានការតាំងចិត្ត និងគោលបំណងខ្ពស់ក្នុងការចូលរួមក្នុងក្រុម | បុគ្គលិកបានធ្វើសមាធិប្រមូលអារម្មណ៍និងស្វែងយល់ពីសារៈសម្ខាន់នៃការប្រជុំរបស់ក្រុមសន្សំប្រាក់ |

**៥).សន្និដ្ឋាន**អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គមជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយដែលទទួលមូលនិធិពីដោយផ្ទាល់ពីអង្គការក្រៅស្រុកខ្លះដូចជាអង្គការ Ecosolidar, Aid et Action, USAID, និង Global Funds តាមរយៈអង្គការខាណា,អង្គការ Save the Children និង Denver University in USA។ដោយអនុវត្តទៅតាមគម្រោងនានាដូចជាៈ គម្រោងកុមារមេគង្គកម្ពុជា, គម្រោងសុខភាព, គម្រោងអប់រំ មូលដ្ឋាន,គម្រោងធ្វើអោយប្រសើរឡើងនូវជីវភាពសហគមន៍ ដែលទាក់ទងនឹងកម្មវិធីការអប់រំដល់កុមារក្រីក្រកុមារងាយរងគ្រោះ កុមារបាត់បង់ឱកាស បង្រឹងការអប់រំសិស្សកំរិតបឋម ពង្រឹងគុណភាពអប់រំតាមសាលា ថែទាំអ្នកជម្ងឺអេដស៍ តាមផ្ទះ សហគមន៍ ជំងឺអេដស៍និជាដើម។ លទ្ធផលសម្រេចបានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ និងចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ជីវភាពរបស់ប្រជាពលរដ្ឋ។

ជាងនេះទៀតអង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គមសំណើសុំឲ្យមានការសហការបន្ថែមទៀតពីសំណាក់អាជ្ញាធរនិងសហគមន៍ពាក់ព័ន្ធ ដើម្បីឲ្យលទ្ធផលនៃការអនុវត្តគម្រោងទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងគម្រោងនិមួយៗ ។

កំពង់ចាម ថ្ងៃទី..... ខែ...... ឆ្នាំ២០១៦

**ប្រធានកម្មវិធី**

បានឃើញនិង.........................

ថ្ងៃទី......... ខែ........... ឆ្នាំ២០១៦

**នាយកប្រតិបត្តិ**